# មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0051

**សម្ភាសន៍ជាមួយឈ្មោះ អ៊ិត ហម ភេទប្រុស អាយុ៦០ឆ្នាំ**

**មុខងារជំនាន់ខ្មែរក្រហមៈ «យោធា»**

**មុខងារបច្ចុប្បន្នៈ «កសិករ»**

**ស្រុកកំណើតភូមិក្បាលដំរី ឃុំតាត្រាវ ស្រុកពួក ខេត្តសៀមរាប**

**រស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០១:៣១:០៣**

**៥៣ទំព័រ**

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ហមៈ ខ្ញុំឈ្មោះអ៊ិត ហម ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយសព្វថ្ងៃហ្នឹង?

ហមៈ យី!ឆ្នាំវកមិនដឹងជាអាយុប៉ុន្មានហើយសើច... ។

ប៊ុនថនៈ ចឹងពូកើតឆ្នាំប៉ុន្មានចឹង?

ហមៈ ឆ្នាំ១៩៥០ប៉ុន្មានទេ មីងអូនមើលអត្តសញ្ញាណប័ណ្ណឲ្យបន្តិចមើល អ្នកជិតនិយាយកើតឆ្នាំ១៩៥០ ។

ប៊ុនថនៈ ចឹងកើតឆ្នាំ១៩៥០ចឹងអាយុ៦០ឆ្នាំ?

ហមៈ បាទ ។

ប៊ុនថនៈ ឥឡូវឆ្នាំ២០១០ បាទ!អាយុ៦០?

ហមៈ ហ្នឹងហើយ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅភូមិអីដែរ?

ហមៈ ភូមិក្បាលដំរី ។

ប៊ុនថនៈ ឃុំ?

ហមៈ ឃុំតាត្រាវ ស្រុកពួក ។

ប៊ុនថនៈ ខេត្តសៀមរាប?

ហមៈ ខេត្តសៀមរាប ។

ប៊ុនថន៖ ពូមានបងប្អូនប៉ុន្មាននាក់?

ហម៖ មាន៤នាក់ ។

ប៊ុនថន៖ មាន៤នាក់ ពូកូនទីប៉ុន្មាន?

ហម៖ ខ្ញុំកូនទី៣ ។

ប៊ុនថន៖ ពូកាលនៅភូមិមានបានចូលរៀនអីទេ?

ហម៖ អត់ បានរៀនបន្តិចៗ ។

ប៊ុនថន៖ បានរៀនប៉ុន្មានឆ្នាំដែរ?

ហម៖ ទេ មិនបានប៉ុន្មានឆ្នាំទេ នៅស្រុកចេះតែដើររៀនទំពាសទៅសើច... ។

ប៊ុនថន៖ រៀននៅក្នុងភូមិ?

ហម៖ បាទ! នៅក្នុងភូមិយើងហ្នឹង ។

ប៊ុនថន៖ បាទ ។

ហម៖ មើលគោផងរៀនបានតិចៗមានអីចេះ ។

ប៊ុនថន៖ កាលហ្នឹងឆ្នាំប៉ុន្មានពូចូលរៀន?

ហម៖ អូ! មិនដឹងជាឆ្នាំប៉ុន្មានទេ កាលពីតូចហ្នឹង ។

ប៊ុនថន៖ រៀនរដ្ឋប្រហារហើយឬមួយក្រោយរដ្ឋប្រហារ?

ហម៖ កាលនោះគេធ្វើសង្គ្រាម អ៊ីខ្ញុំចេះតែចាប់គាត់ខ្លាចគេចាប់ធ្វើទាហាននោះ ។

ប៊ុនថន៖ បាទ ។

ហម៖ មិនដឹងជាឆ្នាំប៉ុន្មានដងកាលហ្នឹង ។

ប៊ុនថន៖ កាលហ្នឹងមានសង្គ្រាម?

ហម៖ សង្គ្រាមតើ សង្គ្រាមស្អីគេទេ ដល់ចឹងទៅខ្ញុំធ្វើឈ្លបជាមួយគេទៅ ដល់ហើយចូលធ្វើកងទ័ពបណ្ដោយទៅ ។

ប៊ុនថន៖ ចូលឈ្លបឆ្នាំណាពូ?

ហម៖ ពិបាកឆ្នាំអត់ដឹងទេ ។

ប៊ុនថន៖ មិនបានដឹងឆ្នាំទេ?

ហម៖ បាទ! នៅស្រុក ។

ប៊ុនថន៖ កាលពេលសង្គ្រាមពូចូលឈ្លបហើយពូ?

ហម៖ ធ្វើឈ្លប ។

ប៊ុនថន៖ ឈ្លបហ្នឹងនៅភូមិយើងឬនៅក្រៅ?

ហមៈ ឈប់នៅភូមិយើងហ្នឹង ភូមិក្បាលដំរី ស្រុកពួកហ្នឹង ដល់នេះទៅចូលធ្វើកងទ័ពស្រុកពួកហ្នឹងបណ្ដោយ ។

ប៊ុនថនៈ ចឹងធ្វើហ្នឹងនៅស្រុកពួក?

ហមៈ ស្រុកពួកដដែលហ្នឹង ។

ប៊ុនថនៈ នៅឆ្ងាយពីផ្ទះពូទេ?

ហមៈ អត់ទេ ជិតដែរ ។

ប៊ុនថនៈ នៅជិតផ្ទះពូ?

ហមៈ បាទ ។

ប៊ុនថនៈ ធ្វើប៉ុន្មានឆ្នាំពូ?

ហមៈ ធ្វើយូរហ្នឹងដែលឯង មានតិចឆ្នាំណាចូលធ្វើតាំងពីឆ្នាំ៧២ ។

ប៊ុនថនៈ ចូលទ័ពស្រុកហ្នឹង៧២?

ហមៈ បាទ!ចូលឆ្នាំ៧២ថ្ងៃទី១០ខែ២ចេះឯង ។

ប៊ុនថនៈ ចឹងធ្វើទ័ពហ្នឹងបានប៉ុន្មានឆ្នាំបានពូចេញមកទៀត?

ហមៈ ធ្វើមើលឡើង៧៥ ឯករាជ្យហ្នឹង ៧៥គេដកខ្ញុំមកភ្នំពេញនេះ ។

ប៊ុនថនៈ បាទ ។

ហមៈ ៧៦គេដកមក ហ្នឹងដកមក៧៦-៧៧-៧៨ យួនចូលហ្នឹងយើងរត់ ។

ប៊ុនថនៈ បាទ ។

ហមៈ រត់មកយើងទៅខ្មែរក្រហមទៀត ។

ប៊ុនថនៈ បាទ ។

ហមៈ ចូលខ្មែរក្រហមទៀតចូល៣២មកគេដកមក៨៥០នេះ ។

ប៊ុនថនៈ ឯករាជ្យហ្នឹងពូទៅនៅណា?

ហមៈ ខ្ញុំទៅភ្នំពេញ ។

ប៊ុនថនៈ ទៅខាងផ្នែកអីវិញពូ?

ហមៈ ក្រសួង៨៧០នោះ នៅខាងលិចទូតចិនខាងលិចទួលទំពូងនោះ នៅធ្វើការជាមួយភ្ញៀវហ្នឹងឯង ។

ប៊ុនថនៈ នៅទូតចិនហ្នឹងតែម្ដង?

ហមៈ បាទ ។

ប៊ុនថនៈ នៅជាប់ហ្នឹង?

ហមៈ ហ្នឹងហើយនៅបានពីរឆ្នាំ ។

ប៊ុនថនៈ នៅទូតចិនហ្នឹងតែម្តង?

ហមៈ បាទ! ធ្វើការជាមួយភ្ញៀវ ។

ប៊ុនថនៈ គេហៅអីវិញកាលហ្នឹង?

ហមៈ ទូតចិនគេហៅក្រសួង៨៧០ ។

ប៊ុនថនៈ ៨៧០?

ហមៈ មុនដំបូងទៅរោងចក្រកែវនោះ ទៅលើកប្រឡាយអីនោះដល់នេះគេដកមកក្មេងៗណាស់ ដកមកនៅកន្លែងភ្ញៀវ ។

ប៊ុនថនៈ ចឹងដំបូងទៅរោងចក្រកែវ?

ហមៈ បាទ! ទៅជីកប្រឡាយអីហ្នឹង ។

ប៊ុនថនៈ ជីកបានរយៈពេលប៉ុន្មានបានពូមកនេះ?

ហមៈ យូរដែរសើច... ស៊ីនំប៉័ងព្រឹកល្ងាច ដល់នេះបានគេដកមកកន្លែងទូតចិនហ្នឹងមើលភ្ញៀវហ្នឹង ធ្វើការដល់៧៧-៧៨យួនចូលមកកំពង់សោមមកខាងពិចនិលអីនេះ ។

ប៊ុនថនៈ ចឹងនៅពេទ្យចិនហ្នឹងគេហៅមន្ទីរ៨៧០?

ហមៈ ក្រសួង៨៧០ ។

ប៊ុនថនៈ ពូនៅហ្នឹងពូនៅធ្វើអីវិញពូ?

ហមៈ នៅអូសត្រីអូសអីហ្នឹង ទៅដល់កំពង់ឆ្នាំងអីនោះ ។

ប៊ុនថនៈ នៅខាងក្រសួងយ៉ាងម៉េចបានជាទៅអូសត្រីវិញ?

ហមៈ ចុះគេឲ្យទៅរកត្រីរកអីនោះ មានអួនមានអីគេអូសកាណូតហ្នឹង ចុះក្រសួងហ្នឹងគេប្រើចឹងចេះតែធ្វើទៅ ។

ប៊ុនថនៈ បាទ! ចឹង៨៧០ហ្នឹងនៅជាមួយពីណាខ្លះពូ?

ហមៈ ៨៧០ហ្នឹងនៅជាមួយពីណាទេ...នៅជាមួយតា ព្រុំ តា ប៉ន ។

ប៊ុនថនៈ ចឹងតាប៉នហ្នឹងជាប្រធានពូ?

ហមៈ គេមិនមែនប្រធានទេ តែគ្រប់គ្រងមន្ទីរដឹងខ្ញុំមិនសូវយល់ដែរ តែឈឺស្កាត់អីគេយកទៅដេកពេទ្យនៅហ្នឹងហើយ ។

ប៊ុនថនៈ ដេកពេទ្យនៅណាវិញពូ?

ហមៈ ដេកពេទ្យកន្លែងតា ព្រុំអីហ្នឹង ។

ប៊ុនថនៈ គាត់ឈ្មោះអីព្រុំ ពូ?

ហមៈ មិនដឹងជាឈ្មោះអីទេពុកែគេហៅសើច...យើងមិនសូវស្គាល់គេយើងក្មេង ។

ប៊ុនថនៈ បាទ ។

ហមៈ នៅកន្លែងចិននោះគេគ្រប់គ្រងឃើញគេមកដែរ  នាំយើងឲ្យនៅកន្លែងទូតចិននោះធ្វើការជាមួយភ្ញៀវជាមួយអី ។

ប៊ុនថនៈ ភ្ញៀវជនជាតិអីវិញពូ?

ហមៈ ភ្ញៀវចិន ។

ប៊ុនថនៈ ចិនច្រើនទេ?

ហមៈ យី!មួយកន្លែងទូតចិនមានតិចណា?

ប៊ុនថនៈ សុទ្ធតែចិន?

ហមៈ ចិនទាំងអស់  ចិនកម្មករហ្នឹង  ខ្មែរយើងក៏កម្មករទាំងស្រីទាំងប្រុស ។

ប៊ុនថនៈ កាលហ្នឹងកម្មករអីវិញ?

ហមៈ កម្មករយើងទៅធ្វើកន្លែងលាងផ្ទះលាងអីហ្នឹង  ចំរាស់ស្មៅអីហ្នឹងជុំជាមួយភ្ញៀវចិនហ្នឹង ។

ប៊ុនថនៈ ចឹងពូក្រៅពីការងារលាងផ្ទះហ្នឹងមានធ្វើអីផ្សេងទៀត?

ហមៈ ទេ  ចប់ពីលាងផ្ទះទៅក៏ទៅលាងស្មៅ ។

ប៊ុនថនៈ ចំរាស់នៅកន្លែងណា?

ហមៈ ចំរាស់នៅកន្លែងទូតចិន  វត្តទួលទំពូងហ្នឹងណាស់អាជាប់និងព្រហ្មហ្នឹង ។

ប៊ុនថនៈ ចឹងពូថាទៅអូសត្រី?

ហមៈ អីនោះគេឲ្យទៅអូសម្តងៗហ្នឹង ។

ប៊ុនថនៈ រយៈពេលប៉ុន្មានបានឲ្យទៅអូសម្តង?

ហមៈ ទៅកន្លះខែមួយខែដឹង  អូសត្រីកំពង់ឆ្នាំងអីណានោះ  កោះក្របីអីនោះ ។

ប៊ុនថនៈ មួយក្រុមពូ?

ហមៈ បាទ ។

ប៊ុនថនៈ ប៉ុន្មាននាក់ក្រុមអូសត្រី?

ហមៈ យី!ទៅគ្នាច្រើនដែរ  បួនដប់នាក់ដឹង ។

ប៊ុនថនៈ ចឹងអូសបានទេ?

ហមៈ អូសបានតើ  គេរាយតែកាណូតទៅយើងទាញ ។

ប៊ុនថនៈ អូសបានយកមកណាវិញ?

ហមៈ យកមក«ក១៩» ។

ប៊ុនថន៖ «ក១៩»?

ហម៖ ប្រាំងចំរេះនេះ ។

ប៊ុនថន៖ ចឹង«ក១៩ហ្នឹងខាងត្រីដែរ»ពូ?

ហម៖ ខាងត្រីដែរ ខាងនេសាទ កាលហ្នឹងមានឃើញភ្ញៀវទៅយកអីហ្នឹង ។

ប៊ុនថន៖ ចឹងពូអូសត្រីហើយបានមក៨៧០វិញ?

ហម៖ ក្រសួង៨៧០វិញ ។

ប៊ុនថន៖ ក្រសួង៨៧០វិញ?

ហម៖ បាទ!និយាយទៅប្រវត្តខ្ញុំវាកម្មណាស់ តាំងពីនេះមកហើយដើរដឹកប្រឡាយ កាលឃួន ចូលបិសគេយកទៅវ៉ៃចោលទៀតនោះ ។

ប៊ុនថន៖ បាទ ។

ហម៖ គេយកទៅធ្វើប្រវត្តិរូបនៅស្ទឹងមានជ័យនោះ ។

ប៊ុនថន៖ កាលហ្នឹងមុនមកពី៨៧០ឬក្រោយ?

ហម៖ កាលនៅ៨៧០ហ្នឹង កន្លែងទូតចិនហ្នឹង ។

ប៊ុនថន៖ ចឹងបន្ទាប់ពីពូធ្វើការរកត្រីអីហើយពូមកធ្វើការនៅ៨៧០វិញ?

ហម៖ មកក្រសួង៨៧០ហ្នឹងហើយ ដល់ធ្វើអាហ្នឹងហើយបានឃួនចូលយើងរត់មកធ្វើខ្មែរក្រហម វិញ ។

ប៊ុនថន៖ បាទ ។

ហម៖ គេដកទៅពិជនិលត្រពាំងក្រឡឹងនោះ តាមផ្លូវរទេះភ្លើងដឹកស្មោដាំនេះយ៉ាប់ដែលហ្នឹង ។

ប៊ុនថន៖ បាទ ។

ហម៖ ទៅវត្តជ័យឧត្តម តាខ្មៅ ណាទៅភ្នួរពេញវាលស្រែនោះខ្ញុំនោះ ។

ប៊ុនថន៖ បាទ ។

ហម៖ យី!កម្មណាស់ដែលហ្នឹងឯង ។

ប៊ុនថន៖ ពូនៅយូរទេ៨៧០ហ្នឹង?

ហម៖ នៅយូរណាស់ពីរឆ្នាំនោះ ។

ប៊ុនថន៖ ចឹងឃើញតែភ្ញៀវចិនអត់មានឃើញជនជាតិអីផ្សេងទៀតទេ?

ហម៖ មានតែចិន ។

ប៊ុនថន៖ គេស្នាក់នៅក្នុងហ្នឹងតែម្ដងឬនៅកន្លែងផ្សេងទៀត?

ហម៖ នៅហ្នឹងឯង ។

ប៊ុនថន៖	ចឹងកន្លែងធំ?

ហម៖	ធំៗដុះគេប៉ុណ្ណណឹ ដែលនៅភ្នំពេញអត់ ។

ប៊ុនថន៖	បាទ!ខ្ញុំធ្លាប់ ខ្ញុំនៅភ្នំពេញតែខ្ញុំមិនដែលចូល ។

ហម៖	នៅជិតវត្តទួលទំពូងឃើញហើយ ខាងនេះខ្ញុំដាក់រថក្រោះទល់មុខគ្នាអាររថក្រោះហ្នឹង ។

ប៊ុនថន៖	ទូតចិនឥឡូវគេធ្វើថ្មីពូ?

ហម៖	គេធ្វើថ្មីហើយ ។

ប៊ុនថន៖	បាទ ។

ហម៖	ខ្ញុំខាតទៅយូរហើយ ។

ប៊ុនថន៖	ខាងលិចទួលទំពូងហ្នឹង?

ហម៖	បាទ ។

ប៊ុនថន៖	ចឹងភ្ញៀវចិននិងធ្វើការនៅ៨៧០ហ្នឹងនៅហ្នឹងដែរ?

ហម៖	បាទ!នៅហ្នឹងដែលអ្នកគ្រប់គ្រងហ្នឹងឈ្មោះ តា ម៉ុល ។

ប៊ុនថន៖	ឈ្មោះ ស្អី ម៉ុលពូ?

ហម៖	អត់ស្គាល់ទេ កាលនោះគេមានបញ្ហាចេះចុះទៅ គេបើឡានបុកបង្គោលភ្លើងទៅ កាលដែលយួនចូលបុកបង្គោលភ្លើងទៅមានបញ្ហាជាមួយខ្ញុំ ថាខ្ញុំណាចេះចុះទៅឲ្យខ្ញុំទៅធ្វើការឲ្យខ្ញុំស្មោះត្រង់ជាមួយបក្ស បើយើងមិនស្មោះត្រង់ដឹងគេយកទៅណា ។

ប៊ុនថន៖	បាទ ។

ហម៖	យើងភ័យអន្ទរគេចេះចុះដាក់លក្ខខ័ណ្ឌជាមួយគេទៅគេដោះលែងមកវិញមក ។

ប៊ុនថន៖	បាទ!យ៉ាងម៉េចបានដាយកពូទៅចឹង?

ហម៖	គេថាយើងក្បត់យ៉ាងម៉េចទេ យើងមិនដឹងអីផង ។

ប៊ុនថន៖	ចឹងតា ម៉ុលនិង តា ប៉ន់មួយណាធំជាង?

ហម៖	តា ប៉ន់គាត់ខាងមន្ទីរខាងនោះ តា ម៉ុល គាត់គ្រប់គ្រងកន្លែងចិនណាស់ ។

ប៊ុនថន៖	បាទ!ចឹងគាត់មានចេះភាសាចិនអីទេ?

ហម៖	ទេ អត់ចេះ ។

ប៊ុនថន៖	ចឹងនិយាយជាមួយចិនយ៉ាងម៉េចទៅ?

ហម៖	ចិនចេះនិយាយដូចយើងចឹងដែរ យើងមុនចូលទៅយើងសួរដែកឈូសយើងសួរចិនទៅចិនប្រាប់ហើយ ។

ប៊ុនថន៖	បាទ ។

ហមៈ ចបសួរទៅគាត់ប្រាប់ហើយយើងចេះតែចាំនៅហ្នឹង វាប្រាប់ទៅ ។

ប៊ុនថនៈ បាទ!ចឹងពូចេះទេពូធ្វើការនៅហ្នឹង?

ហមៈ អត់ទេ ពីមុនមកចេះតែស្តាប់បានចិន ប្រាប់ឲ្យទៅយកប៉ែលចេះចុះចិនប្រាប់ទៅយើងទៅយកបាន ។

ប៊ុនថនៈ បាទ!ចេះនិយាយដែលពូ?

ហមៈ អត់ទេ ។

ប៊ុនថនៈ តែស្តាប់បាន?

ហមៈ ស្តាប់បាន ។

ប៊ុនថនៈ បាទ ។

ហមៈ កាលទៅយកប៉ែលចិនគេថាយ៉ាងម៉េចទេ ចិនគេនិយាយទៅ ។

ប៊ុនថនៈ ចឹងចិនហ្នឹងសុទ្ធតែកម្មករទេ អត់មានអ្នកធ្វើការនៅ?

ហមៈ កម្មករ អត់ទេធ្វើការគេធំៗ មេគេធំៗគានេះគេមកប្រជុំម្តងហើយ ។

ប៊ុនថនៈ ប្រជុំតែចិនឬមានខ្មែរចូលរួមដែរ?

ហមៈ ខ្មែរយើងមានតើដូចជាពួកខ្ញុំនៅហ្នឹង មើលគេបញ្ចាំងកុនបញ្ចាំងអីហ្នឹង អត់មានឲ្យពីណាចូលទេ កងទ័ពយាម ។

ប៊ុនថនៈ បញ្ចាំងកុនហ្នឹងបញ្ចាំងពីអីវិញ?

ហមៈ ទេ មិនដឹងជាគេបញ្ចាំងពីអីផង ។

ប៊ុនថនៈ ចឹងពូអត់ដែលបានចូលមើលទេ?

ហមៈ ចូលមើលដែលតែមិនបានចាប់អារម្មណ៍ ។

ប៊ុនថនៈ ការបញ្ចាំងហ្នឹងជាឯកសារចិនឬមួយឯកសារខ្មែរ?

ហមៈ ទេ មិនដឹងជាខ្មែរមិនដឹងជាស្អីទេ ភ្លេចអស់ហើយមិនសូវគិតគូរផង សូម្បីតែខ្សែគ្រួបងប្អូនឲ្យកាលទៅធ្វើសង្គ្រាមនោះក្រវាត់ចោលអស់រលីង កាលគេហៅទៅធ្វើប្រវត្តិរូបនោះក្រវាត់ចោលអស់រលីង ។

ប៊ុនថនៈ ក្រវាត់ចោលអីវិញពូ?

ហមៈ ទេសគ្រួដែលការពារខ្លួនយើង កាលយើងខ្មែរក្រហមនោះណាស់ ក្រវាត់ចោលអស់រលីងហើយ ។

ប៊ុនថនៈ យ៉ាងម៉េចបានក្រវាត់ចោល?

ហមៈ ចុះគេមិនទុកចិត្តយើង គេឆែកឆេរខ្ញុំក្រវាត់ចោលអស់រលីងស្តាយ ម៉ែឪបងប្អូនខ្ញុំឲ្យ ។

ប៊ុនថន៖ ចឹងពូនៅក្រោយតា ម៉ុលហ្នឹងគាត់ជាអ្នកគ្រប់គ្រង?

ហម៖ គេគ្រប់គ្រង់ទាំងអស់ ។

ប៊ុនថន៖ ចឹងកាលហ្នឹងមានបែងចែកអីជាកងទេ?

ហម៖ មានពីរកង តា ដានមួយកងខ្ញុំនៅជាមួយតា ម៉ុល ។

ប៊ុនថន៖ ចឹងកងនារីនៅខាងតា ដាន?

ហម៖ ទេ កងនារីគេនៅផ្សេងទេ ប្អូនកងគេទៅខាងនោះ ព្រឹកឡើងបានគេមកធ្វើការ ។

ប៊ុនថន៖ ចឹងមួយកងមានគ្នាប៉ុន្មាននាក់ពូ?

ហម៖ មួយកងមានគ្នា៣០នាក់ ។

ប៊ុនថន៖ ចឹងពីរកងមានគ្នា៦០នាក់?

ហម៖ បាទ ។

ប៊ុនថន៖ ចឹងខាងចិនគេមានមេគ្រប់គ្រងផ្សេង?

ហម៖ ចិនគេផ្សេងតើ យើងផ្សេង យើងនៅនោះត្រូវដឹកអាងដឹកអី ត្រូវដឹកអាំងគេប្រើឲ្យយើងដឹកទៅ ។

ប៊ុនថន៖ យើងរស់នៅក្នុងអគារបរវេនតែមួយទេ?

ហម៖ បរវេនតែមួយទេ តែយើងដេកខាងចិនគេដេកកណ្ដាល យើងមកជាប់វត្តទួលទំពូងហ្នឹងមានផ្ទះតូចៗហ្នឹងនៅដេក ។

ប៊ុនថន៖ ចិនមានច្រើននាក់ដែលពូ?

ហម៖ ចិនមានច្រើនដែលហ្នឹងកម្មករ ។

ប៊ុនថន៖ ចឹងខាងតា ប៉ន់គាត់នៅខាងណាវិញ?

ហម៖ គេនៅមន្ទីរគេនៅក្នុង ។

ប៊ុនថន៖ នៅក្នុងបរវេនជិតវត្តទួលទំពូងដែលឬមួយនៅផ្សេង?

ហម៖ គេនៅខាងនោះ ។

ប៊ុនថន៖ ចឹងពូនៅ៨៧០ជាមួយតា ប៉ន់អីដែរ?

ហម៖ បាទ! តា ប៉ន់ តា ព្រំ ។

ប៊ុនថន៖ ចឹងក្រៅពីតា ប៉ន់មានពីណាផ្សេងទៀត?

ហម៖ ទេ មិនស្គាល់ទេ ។

ប៊ុនថន៖ ចឹងពូមានដែលជួបគាត់ទេ តា ប៉ន់?

ហម៖ ជួបដែលតើ ។

ប៊ុនថន៖ គាត់ខស្សាហ៍មកមើលកន្លែងពូទេ?

ហម៖ ទេ គេមិនដែលមកទេ ស្គាល់កាលដែលគេរៀបចំយើងឲ្យមកនៅជាមួយភ្ញៀវបានគេមក គេប្រាប់ឲ្យយើងកាត់សក់កាត់អីឲ្យអស់ ខ្ញុំស្មានថាបានទៅស្រុកចិនសើច... ឃើញគេដាក់ចានឆ្នាំងមកឃើញចិនព្រៀតមក ។

ប៊ុនថន៖ កាលហ្នឹងយកពូពីណាមក?

ហម៖ យកពីកន្លែងមន្ទីរគេមក ពីរោងចក្រកែវមក ។

ប៊ុនថន៖ ពីរោងចក្រកែវ?

ហម៖ បាទ!គេដកអីនោះមក ។

ប៊ុនថន៖ ដកច្រើននាក់ដែលពូ?

ហម៖ អី!ច្រើនដែរ វាមិនបានរាប់ផងកាលហ្នឹង មកដល់គេថាបួនៗក្បួយៗកាត់សក់ទៅ ទៅចិនហើយយើងនេះ នាំគ្នាកាត់សក់កាត់អី ។

ប៊ុនថន៖ ចឹងពូនឹកស្មានថាបានទៅចិនហើយ?

ហម៖ បាទ!ស្មានថាទៅចិន ។

ប៊ុនថន៖ តែកាលទៅហ្នឹងមានចិនទៅជាមួយដែរ?

ហម៖ អត់ទេ មកវត្តទួលទំពូងហ្នឹងចេញមកទទួលយើង ។

ប៊ុនថន៖ អត់ទេ និយាយថាគេទៅយកពូនៅរោងចក្រកែវ?

ហម៖ អរ!អាហ្នឹងខ្មែរយើងហ្នឹងអ្នកទៅយក ។

ប៊ុនថន៖ តា ប៉ន់ហ្នឹង?

ហម៖ អត់ទេ តា ព្រំទេ គេហៅមកហ្នឹង ដឹងថាពីណាគេហៅមកផង ។

ប៊ុនថន៖ បាទ ។

ហម៖ មកដល់កន្លែងមន្ទីរគេ គេឲ្យកាត់សក់កាត់អីហ្នឹងដាក់ឆ្នាំងដាក់ចានអីជិះឡានទៅចិនហើយក្បួយៗឯង ។

ប៊ុនថន៖ ចឹងអរទេ ពូថាបានទៅចិនហ្នឹង?

ហម៖ អរដែលហ្នឹងសើច... តែដល់ជិះឡានមកបានបន្តិចឃើញភ្ញៀវចេញមក ខ្ញុំថាអូ៎នៅកន្លែងនេះ ។

ប៊ុនថន៖ មានចិនមកទទួល?

ហម៖ បាទ!មកចាប់ដៃអីហ្នឹងចុះទៅធ្វើការ ។

ប៊ុនថន៖ ចឹងកាលពូនៅក្នុងរោងចក្រកែវហ្នឹងពូធ្វើការក្នុងរោងចក្រហ្នឹងតែម្តង?

ហមៈ ទេ នៅអែបរោងចក្រកែវហ្នឹង កន្លែងតា គី ។

ប៊ុនថនៈ តា គី?

ហមៈ តា គីជាអ្នកគ្រប់គ្រង បង ហ៊ាន តា អឿន អ្នកគ្រប់គ្រងតែតា គីជាមេធំ ។

ប៊ុនថនៈ ចឹងតា គីគាត់ខាងទាហានដែលប្តូខាងមន្ទីរអីផ្សេង?

ហមៈ មិនមែនទាហានទេ អាហ្នឹងគេចាប់យើងទៅពីណាពីណីទៅគេបញ្ជូនយើងទៅហ្នឹងឲ្យគាត់ទៅ កាលនោះ គាត់ជាអ្នកគ្រប់គ្រង ។

ប៊ុនថនៈ គាត់គ្រប់គ្រង់នៅហ្នឹង?

ហមៈ ហ្នឹងហើយ ។

ប៊ុនថនៈ អត់មានដាក់មន្ទីរអីទេ?

ហមៈ មន្ទីរ ។

ប៊ុនថនៈ គេហៅមន្ទីរស្អីវិញ?

ហមៈ មិនដឹងជាមន្ទីរស្អីទេ មន្ទីរតា ពិន ។

ប៊ុនថនៈ ច្រើននាក់ទេពូនៅហ្នឹង?

ហមៈ អូស!ទាំងស្រីទាំងប្រុស?

ប៊ុនថនៈ មានគ្នាប្រហែលជាប៉ុន្មាននាក់ទៅ?

ហមៈ រាប់រយរាប់ពាន់ដឹង ដីកប្រឡាយធ្វើស្រែអូសដល់ហើយខ្ញុំដើរតែភ្នំហ្នឹង ។

ប៊ុនថនៈ ភ្នំគោធម្មតាហ្នឹង?

ហមៈ ភ្នំគោក្របី ។

ប៊ុនថនៈ ចឹងពូចេញពីសៀមរាបទៅពូទៅនេះតែម្តង?

ហមៈ ខ្ញុំចេញពីស្រុកពួកទៅ ខ្ញុំទៅនៅសៀមរាប ដល់ទៅនៅសៀមរាបបានប៉ុន្មានថ្ងៃហ្នឹងអត់នៅ គេថាក្មេងពេក គេអត់ឲ្យទៅ តាមួយប្រុងចាប់ទុកហ្នឹង ខ្ញុំអត់នៅគេហៅឈ្មោះក្រោយគេ ក៏ឡើងឡានមក គាត់មិនចង់ឲ្យទៅណា ។

ប៊ុនថនៈ គាត់ថាពូក្មេងពេក?

ហមៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងពូមានអាយុប៉ុន្មានហើយ?

ហមៈ ដឹងអាយុប៉ុន្មានទេ កាលហ្នឹង គាត់ថាទៅលីសែងមិនរួចទេ ក្មួយឯងកុំទៅនៅរៀនហ្នឹង ហើយ ។

ប៊ុនថនៈ គាត់ឲ្យពូនៅរៀន?

ហមៈ បាទ! នៅរៀនហ្នឹងហើយ ឡានក៏មានទឹកមុជក៏មានរៀនអក្សរហ្នឹងទៅ ប៉ុន្មាននាក់ទេកាល ហ្នឹងគាត់កាត់ទោស បើនៅជាមួយតាហ្នឹងក៏យ៉ាប់ដែរ គេចាប់ ។

ប៊ុនថនៈ គាត់ឈ្មោះអីវិញលោកពូ?

ហមៈ មិនដឹងជាឈ្មោះ តា ស្អីទេ គាត់ក្តាប់ខាងហិរញ្ញវត្ថុ ។

ប៊ុនថនៈ កាលហ្នឹងគេកាត់មានកងអីដែរ?

ហមៈ អត់ទេ កាលហ្នឹងថាគាត់ធ្វើខាងអីទេ ខាងបូព៌ា ។

ប៊ុនថនៈ តែពូនៅកងប៉ុន្មានកាលហ្នឹង នៅពួកនេះ?

ហមៈ កាលហ្នឹងនៅទាហានមិនដឹងកងលេខប៉ុន្មានទេ កងនៅស្រុកហ្នឹង ។

ប៊ុនថនៈ កាលហ្នឹងមានប្រធានវរៈប្រធានកងពលអីដែរ?

ហមៈ អត់ទេ អាចមានលេខអីដែលតែខ្ញុំក្មេច ដល់នេះគេដកខ្ញុំទៅ៤៥០ ៤៥០ហ្នឹងតា ប៉ែត តា ឡុងហ្នឹងនៅសមរភូមិកែងបារាយណ៍គេឲ្យទៅពង្រឹងហ្នឹងឯង ។

ប៊ុនថនៈ បាទ ។

ហមៈ ឲ្យទៅពង្រឹងហើយគេឲ្យ ទៅវ៉ៃអា៨៧០នៅភ្នំបូកភ្នំអីភ្នំធំនោះ វ៉ៃអាហ្នឹងរួចត្រឡប់មក ស្រុកវិញឯករាជ្យទៅ ឯករាជ្យគេរើសយើងប្រវត្តិរូបដែលម៉ែឪបងប្អូនយើងអត់ធ្វើទា ហាន គេរើសប្រវត្តិរូបឲ្យទៅភ្នំពេញ ។

ប៊ុនថនៈ អត់មានធ្វើទាហានខាងនេះ?

ហមៈ ខាងក្នុងនោះ បើអត់ជាប់មានប្រវត្តិហ្នឹងគេយកយើងទៅភ្នំពេញទៅ ។

ប៊ុនថនៈ ចឹងនៅទ័ពស្រុកហ្នឹងគេឲ្យឡើងវ៉ៃដែរ?

ហមៈ វ៉ៃ វ៉ៃខាងផ្តល់ជាតិយើងរាល់ថ្ងៃនេះសើច.. វ៉ៃជាមួយខាងក្នុង ។

ប៊ុនថនៈ ពីណាដឹកនាំពូកាលហ្នឹង?

ហមៈ កាលហ្នឹងតាៗយើងហ្នឹងឯង ទៅបញ្ជាតែម្តង ។

ប៊ុនថនៈ ទៅបញ្ជាផ្ទាល់តែម្តង?

ហមៈ ទេ គាត់ទៅម្តងៗ ។

ប៊ុនថនៈ ចឹងពូបានវ៉ៃទៅកន្លែងណាខ្លះពូ?

ហមៈ យី! ដើរវ៉ៃមកដល់ថ្នល់ក្រហមអី កំពង់ថ្កូវអីហ្នឹងណាស់ វ៉ៃច្រើនហ្នឹងឯងរឿងវ៉ៃហ្នឹង ។

ប៊ុនថនៈ ចឹងដល់ឯករាជ្យហើយបានពូ?

ហមៈ ទៅភ្នំពេញ ។

ប៊ុនថនៈ ទៅសៀមរាប?

ហមៈ ទៅភ្នំពេញ គេដកពីពួកទៅសៀមរាប គេដកពីសៀមរាបទៅភ្នំពេញ ។

ប៊ុនថនៈ យ៉ាងម៉េចបានជាពួចង់ទៅ ឃើញគេទៅអស់ហើយបានពួចង់ទៅ?

ហមៈ ចុះមុនដំបូងឃើញៗទៅយ៉ាងច្រើនចេះតែចង់ទៅហ្នឹងគេទៅសើច...ស្រីៗទៅដល់សៀមរាបពេញហ្នឹង អាខ្លះគេយកមកផ្ទះគេដកទៅ ខ្លះគេមិនចង់ទៅ ។

ប៊ុនថនៈ ចឹងកាលទៅពីសៀមរាបហ្នឹងឪពុកម្តាយពូដឹងទេ?

ហមៈ គាត់អត់ដឹងផង ខ្ញុំធ្វើទំនប់នៅបារាយណ៍ហ្នឹងគេដកទៅ ។

ប៊ុនថនៈ ធ្វើទំបន់អីគេ?

ហមៈ ធ្វើទំនប់ហូរមកអាទឹកវិលហ្នឹង ដឹកថ្មពីសៀមរាបមកដាក់បិតៗ គេអ្នកបិតខ្ញុំអ្នកដឹកឲ្យគេ ។

ប៊ុនថនៈ បាទ ។

ហមៈ ទំបន់បារាយណ៍ចេញពីខាងត្បូង ។

ប៊ុនថនៈ បារាយណ៍?

ហមៈ បារាយណ៍ទឹកថ្លាហ្នឹង ។

ប៊ុនថនៈ ចឹងទំនប់ធំហ្នឹងពូធ្វើនៅហ្នឹងទេ?

ហមៈ ធ្វើនៅហ្នឹងឯង ធ្វើហើយបានគេរើសប្រវត្តិរូបយើងដកមក ។

ប៊ុនថនៈ បាទ!ខ្ញុំឃើញហើយទំនប់ខ្ពស់ អាទំនប់ប្រហូរចេញមកហ្នឹងពូ?

ហមៈ បាទ!ហ្នឹងហើយ ។

ប៊ុនថនៈ យើងជិះឡានឡើងទៅលើទៅបត់ឆ្វេងផ្ទះគេលក់?

ហមៈ យើងគ្រាន់តែលើកថ្មដាងគេជាអ្នកបិតទៅណាស់ យើងកម្មករ ។

ប៊ុនថនៈ ចឹងកាលហ្នឹងមិនទាន់មានទំនប់ទេ?

ហមៈ មានតែវាចាស់ ចាស់ហើយវារៀបថ្មៗ ។

ប៊ុនថនៈ ចឹងធ្វើបន្ថែមទៀតពូ?

ហមៈ បាទ!ដល់ខ្ញុំមកលើកក្រោយទៀតកាន់តែប្លែកគេធ្វើទៀត ។

ប៊ុនថនៈ ធំណាស់ខ្ញុំមើលទៅដូចភ្នំចឹង ។

ហមៈ បាទ ។

ប៊ុនថនៈ ចឹងកាលធ្វើទំនប់ហ្នឹងមនុស្សច្រើនទេ?

ហមៈ ច្រើនណាស់ ។

ប៊ុនថនៈ សុទ្ធតែកងទ័ពធ្វើឬក៏មានកំលាំង?

ហមៈ កងទ័ពធ្វើតែដឹកថ្មពីសៀមរាបមក ។

ប៊ុនថន៖ ពូអ្នកដឹកថ្មមក?

ហម៖ ខ្ញុំជាអ្នកដឹកថ្មមកឲ្យគេហ្នឹងយប់ឡើងជួយលើកដាក់គេទៅ មានឆេះភ្លើងទាល់ព្រឹកទៅ ។

ប៊ុនថន៖ ចឹងធ្វើទាំងថ្ងៃទាំងយប់?

ហម៖ បាទ ។

ប៊ុនថន៖ ចឹងពូធ្វើទាល់តែហើយបានពូមកភ្នំពេញ?

ហម៖ ដល់ហើយគេដកទៅ ។

ប៊ុនថន៖ ធ្វើរួចទំនប់ហ្នឹង?

ហម៖ ធ្វើហើយហ្នឹងគេដក ។

ប៊ុនថន៖ ធ្វើយូរទេពូទំនប់ហ្នឹង?

ហម៖ យី!ដឹងធ្វើប៉ុន្មានខែទេ មិនបានគិតរឿងខែរឿងអីផងគិតតែពីសប្បាយ ។

ប៊ុនថន៖ កាលហ្នឹងពូនៅក្មេង?

ហម៖ នៅក្មេងសប្បាយជិះឡានហោទៅសើច...មានពិបាកអី ។

ប៊ុនថន៖ តែទំនប់ហ្នឹងពីណាជាអ្នកគ្រប់គ្រង?

ហម៖ អត់ដឹងទេ យើងអត់យល់ផង ។

ប៊ុនថន៖ តែខាងកងទ័ព?

ហម៖ ខាងកងទ័ពអ្នកដឹកថ្មដឹកអីយកមកឲ្យគេធ្វើទៅ ហូបបាយទៅគេដឹកត្រីប្រាមកឲ្យស៊ីទាំងឡាន ៗហ្នឹងមានពិបាកអី យើងក្មេងចេះតែដឹកទៅ ។

ប៊ុនថន៖ ចឹងទំនប់ដីដែលចាក់ហើយហ្នឹង កាលហ្នឹងមានស្រាប់ទេពូ?

ហម៖ មានស្រាប់តែវាបែកបាក់ហើយវាចាស់ ។

ប៊ុនថន៖ ចឹងទំនប់ដែលនៅសល់ហ្នឹងតាំងពីសម័យពូលើកតើអី?

ហម៖ យី!តាំងពូយូរនោះ ។

ប៊ុនថន៖ និយាយថាទំនប់ពូទៅឃើញរាល់ថ្ងៃហ្នឹង សេលសល់តាំងពូធ្វើ?

ហម៖ តាំងពីខ្ញុំធ្វើអាថ្មនោះ ។

ប៊ុនថន៖ នៅរាល់ថ្ងៃហ្នឹង?

ហម៖ ហ្នឹងហើយអាចេញមកត្បូងចឹងនោះ ។

ប៊ុនថន៖ បាទ ។

ហម៖ មានទ្វារគេបិទបើកនោះនៅតែហ្នឹងឯង បើមកចេះខ្ញុំអត់បានធ្វើទេ មកក្រោមមកខាងទឹកនេះ ។

ប៊ុនថន:	ចឹងពូធ្វើខាងត្បូងវិញ?
ហម:	ធ្វើខាងត្បូង ។
ប៊ុនថន:	ចឹងអាខាងជើងអាធំនេះ?
ហម:	អាហ្នឹងមិនដែលធ្វើទេ ។
ប៊ុនថន:	ខ្ញុំទៅឃើញតែអាខាងជើង ចឹងពូធ្វើហើយបានដកពីហ្នឹងមកភ្នំពេញតែម្ដង?
ហម:	បាទ!អូរប្រវត្តខ្ញុំកម្មណាស់ ។
ប៊ុនថន:	ចឹងកាលដកដំបូងហ្នឹងគេបញ្ជូនទៅរោងចក្រកែវតែម្ដងឬយ៉ាងម៉េច?
ហម:	មុនដំបូងខ្ញុំប្រាប់ មុនដំបូងខ្ញុំទៅនៅកន្លែងមុខវាំង គេយកទុកចោលមួយយប់ពីរយប់នោះដល់នេះគេបំបែកគ្នា បំបែកគ្នាទៅបូរីកីឡា ។
ប៊ុនថន:	បូរីកីឡា?
ហម:	ហ្នឹងហើយកាត់ស្មៅកាត់អីអស់ ដឹកស្មៅទៅចោលណាណីអីទេ ដើរលាងផ្ទះគេអាផ្ទះចេះៗលាងផ្ទះអីអស់កាត់ស្មៅអស់គេដកទៅរោងចក្រកែវ ។
ប៊ុនថន:	រោងចក្រកែវ?
ហម:	បាទ!ដកទៅរោងចក្រកែវប៉ុន្មានខែហ្នឹងស៊ីនំប៉័ងព្រឹកល្ងាច បបរអីផងបានគេសេរមកទូតចិននេះ ។
ប៊ុនថន:	កាលដាក់មុខវាំងហ្នឹងកន្លែងអីវិញពូ?
ហម:	មិនដឹងជាកន្លែងស្អីទេ គេដាក់នៅពេលយប់នោះគេចេះតែដាក់ទៅចេះតែឡើងដេកទៅ ។
ប៊ុនថន:	ច្រើននាក់ទេពូ?
ហម:	យី!គេដាក់ពីសៀមរាបមកឡើងប៉ុន្មានឡានានោះ ។
ប៊ុនថន:	ចឹងនៅដេកហ្នឹងទាំងអស់ហើយបានគេបែងចែកមកតាមក្រោយ?
ហម:	មានពីណាមកហៅយកចេះហ្នឹងឡើងប៉ុន្មានថ្ងៃនោះ ។
ប៊ុនថន:	ចឹងអត់មានសួរថាមកពីខេត្តណាៗអីទេពូ?
ហម:	អត់មានពីណាគេសួរផង ស្រាប់បានពីរបីថ្ងៃដែលបានគេមករើសយកបែកគ្នាបណ្ដោយ ។
ប៊ុនថន:	ចឹងពីសៀមរាបទៅមានគ្នាប៉ុន្មាននាក់ដែរ ទៅកន្លែងរោងចក្រកែវ?
ហម:	យី!កាលហ្នឹងច្រើនមែនទែន ។
ប៊ុនថន:	ពូនៅស្គាល់គ្នាទេអ្នកដែលទៅហ្នឹង?
ហម:	ស្គាល់គ្នាតើ នោះអាឈរមួយនោះ អាមួយហ្នឹងនៅនោះជួបគ្នាតែមួយហ្នឹងទេ ផុតពីនោះគេទៅស្រុកអស់ហើយ ខ្ញុំទៅជួបនៅស្រុក ។

ប៊ុនថន៖ បាទ ។

ហម៖ ធ្លាក់ដល់ស្រុកហើយ ទៅស្រុកច្រើនមែនទែន អត់តែខ្ញុំជួបគ្នាអាឈរមួយនោះ ។

ប៊ុនថន៖ នៅជាមួយពូហ្នឹង?

ហម៖ បាទ!អាផ្ទះខាងនោះផ្ទះថ្មហ្នឹងខាងលិចហ្នឹងឈ្មោះអា ឈរ ។

ប៊ុនថន៖ បាទ ។

ហម៖ នៅស្រុកជាមួយខ្ញុំដែលអាហ្នឹង ។

ប៊ុនថន៖ នៅសៀមរាបជាមួយពូដែរ?

ហម៖ នៅស្រុកពួកជាមួយគ្នាហ្នឹង នៅជួបតែអាមួយហ្នឹងឯងផុតពីហ្នឹងគេទៅស្រុកអស់ទៅ ។

ប៊ុនថន៖ ទៅរោងចក្រកែវជិតមួយឆ្នាំហើយ?

ហម៖ ទេ មិនដឹងជាប៉ុន្មានទេ អត់គិតមកដឹកប្រឡាយជាន់ស្រូវជាន់អី កាលហ្នឹងស្រេចតែគេប្រើ បើមិនធ្វើតាមគេមិនបានទេ ។

ប៊ុនថន៖ តែហូបអីបានហូបឆ្អែតទេ?

ហម៖ ទេ នំប៉័ងល្ងាចទៅជួនណាបាយព្រឹកទៅ ជួនណានំប៉័ងល្ងាចទៅ ។

ប៊ុនថន៖ នំប៉័ងសាបយើងហ្នឹង?

ហម៖ នំប៉័ងមានសម្លឲ្យយើងហូប ចេះតែតស៊ូនិងគេទៅ ។

ប៊ុនថន៖ ចឹងពេលមកទួតចិន?

ហម៖ បានស៊ីឆ្អែត ។

ប៊ុនថន៖ ចឹងនៅទួតចិននេះពូធ្វើតែការងារសម្អាតផ្ទះទេ?

ហម៖ សម្អាតផ្ទះដឹកស្មៅ ដឹកអាងស្រេចតែគេប្រើ ចូកដីវ៉ិញរទេះឲ្យតែគេប្រើយើងធ្វើទៅ ។

ប៊ុនថន៖ តែនិយាយថាកន្លែងដែលពូនៅហ្នឹងពីណាជាអ្នកកាន់កាប់?

ហម៖ តា ម៉ុល ។

ប៊ុនថន៖ ចឹងតា ម៉ុលធំជាងគេ?

ហម៖ បាទ ។

ប៊ុនថន៖ ចឹងគាត់នៅរស់តើ?

ហម៖ មិនដឹងជាយ៉ាងណា ដល់មកដឹកដីជាមួយពួកខ្ញុំនៅជ្រៃខត្តមនេះដឹងសន្លត់មិនដឹងជាយ៉ាងម៉េចគាត់ ។

ប៊ុនថន៖ បាទ ។

ហម៖ កាលហ្នឹងគេសែងទៅពេទ្យ១៧ហ្នឹង ដឹងជាយ៉ាងណា ។

ប៊ុនថនៈ ជីកដីនៅណា?

ហមៈ ជីកដីនៅវត្តជ្រៃឧត្តម ជីកប្រឡាយណាស់ ជីកប្រឡាយរាប់គីឡូអែបផ្លូវរថភ្លើង ។

ប៊ុនថនៈ ចឹងមកជីកប្រឡាយដែរ?

ហមៈ គេដកមក គេដកមកជីកប្រឡាយមកជួបពួកខ្ញុំហ្នឹង ជីកប្រឡាយលុងទៅក្រោមដែកស្បែង បុកទៅកប់គាត់ទៅ ឃើញគេសែងទៅពេទ្យ១៧ ។

ប៊ុនថនៈ បាទ ។

ហមៈ ខ្ញុំខឹងគាត់ដែលគាត់ធ្វើបាបខ្ញុំ ។

ប៊ុនថនៈ ចឹងកាលគាត់ទៅជួបពូ គាត់អត់មានគ្រប់គ្រងពូទៀតទេ?

ហមៈ អត់ទេ ផ្សេងគ្នាហើយ គាត់គេដកមកក្រោយខ្ញុំ ខ្ញុំមកមុន ។

ប៊ុនថនៈ ក្រោយពីនេះពូនិយាយប្រាប់ខ្ញុំម្តងហើយថាទៅអូសត្រីអីហ្នឹង?

ហមៈ កាលហ្នឹងខ្ញុំនៅប្រាំងចំរេះ ។

ប៊ុនថនៈ តែពូនិយាយថានៅក្នុងក្រសួង?

ហមៈ ក្រសួង៨៧០ហ្នឹងហើយ ។

ប៊ុនថនៈ តែនៅប្រាំងចំរេះ?

ហមៈ បាទ! ប្រាំងចំរេះ«ក១៩»ហ្នឹង ។

ប៊ុនថនៈ «ក១៩»ហ្នឹងដាក់ន្លេងអីវិញ?

ហមៈ ដាក់ន្លេងរកត្រី គេចិញ្ចឹមត្រី ត្រីអីគេទេចាំលក់ឲ្យភ្ញៀវអីគេដឹង ។

ប៊ុនថនៈ ចឹងមានលក់ដែលកាលហ្នឹង?

ហមៈ ដឹងឃើញភ្ញៀវទៅយកលក់ដឹង ។

ប៊ុនថនៈ លក់ឬមួយគេបែងចែកឲ្យ?

ហមៈ ដឹងគេបែងចែកឲ្យដឹងយ៉ាងម៉េចឃើញតែគេទៅចាប់ អាគេចិញ្ចឹមក្នុងទឹកហ្នឹង ឃើញគេទៅដួសយកមក ។

ប៊ុនថនៈ ចឹងពូទៅមកជាមួយមន្ទីរនៅទូតចិនហ្នឹង?

ហមៈ បាទ! នៅមន្ទីរជុំគ្នាហ្នឹង ។

ប៊ុនថនៈ ជាមួយគ្នាហ្នឹង?

ហមៈ បាទ ។

ប៊ុនថនៈ តែពូបែងចែកទៅនៅខាងនោះវិញ?

ហមៈ បាទ! ស្រេចតែគេត្រូវការ គេរើស ។

ប៊ុនថន៖ នៅហ្នឹងក្រៅពី?

ហម៖ សុទ្ធតែក្រសួង៨៧០ទាំងអស់ ចាប់ពី"ក១០"មក ។

ប៊ុនថន៖ ចឹងពូមានដែលយកត្រីមកក្រសួងមកភ្នំពេញទេ?

ហម៖ អត់ទេ គេដែលប្រើយើងនោះ ការងារយើងផ្សេង ពួកគេផ្សេងយើងជាកម្មករគេ គេដែលប្រើយើង ។

ប៊ុនថន៖ "ក១៩"ហ្នឹងពូមានធ្វើអីទៅហ្នឹង?

ហម៖ រកត្រីហ្នឹងឯង អូសត្រី ទៅដល់កំពង់ឆ្នាំង ។

ប៊ុនថន៖ ចឹងដល់ក្រោយមកគេដកពូទៅធ្វើប្រវត្តិរូបអីនោះ?

ហម៖ នៅកន្លែងទូតចិនតែម្តង ដល់ហើយយួនចូលនោះ៧៧-៧៨ហ្នឹង មានបញ្ហាយ៉ាងម៉េចទេ បានគេដកយើងទៅធ្វើប្រវត្តិរូបនៅស្ទឹងមានជ័យនោះ ។

ប៊ុនថន៖ បាទ ។

ហម៖ តា ម៉ុលហ្នឹងជាអ្នកនាំទៅ គេយាមមានគ្នាគេឡើងពីរបីនាក់នោះ ។

ប៊ុនថន៖ គេដកច្រើនគ្នាទេ?

ហម៖ ដកគ្នា៥ ទៅ៦នាក់នោះ តែបែកគ្នាគេធ្វើនេះម្តងនោះម្តង ។

ប៊ុនថន៖ ចឹងពូប៉ុន្មាននាក់?

ហម៖ ខ្ញុំតែឯងទេ កាលធ្វើហ្នឹងទៅតែឯងទេ ដកគ្នាបួនប្រាំប្រាំមួយនាក់នោះ តែគេធ្វើផ្សេងៗគ្នាណាស់ ។

ប៊ុនថន៖ បាទ ។

ហម៖ យើងនេះក្រោយគេ ។

ប៊ុនថន៖ ដកទៅស្ទឹងមានជ័យហ្នឹងនៅកន្លែងអីវិញពូ?

ហម៖ ទេ អាកន្លែងសម្ងាត់គេហ្នឹង ។

ប៊ុនថន៖ មានផ្ទះមានអីទេ?

ហម៖ មាន ។

ប៊ុនថន៖ ទៅហ្នឹងពីណាជាអ្នកធ្វើប្រវត្តិរូបពូ?

ហម៖ តា ម៉ុលហ្នឹង ។

ប៊ុនថន៖ គេសួរយើងអីខ្លះ?

ហម៖ គេសួរយើងនៅជាមួយពីណា ចេះចុះទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហមៈ ខ្ញុំថា ខ្ញុំនៅទ័ពស្រុកជាមួយបងយហ៊ានអីហ្នឹង គេថាយើងក្បត់ ខ្ញុំថាខ្ញុំអត់មានបានដឹងរឿងក្បត់រឿងអីទេ ខ្ញុំមិនបានដឹងអីទេ ។

ប៊ុនថនៈ បាទ ។

ហមៈ គេថាឆ្លើយឲ្យត្រង់មកបានអ្នកឯងរស់ បើអ្នកឯងឆ្លើយមិនត្រង់ខ្សែភ្លើងឆក់ឥឡូវហើយហ្នឹងខ្ញុំនិយាយប្រាប់ឲ្យអស់តែម្តង ហើយមានគេយាមបីនាក់ ឈ្មោះ រៀមឈ្មោះ រុំ ជាអ្នកយាម តា ម៉ុលជាអ្នកសរសេរ គេសម្លុតខ្ញុំមែនទែនណាស់ ។

ប៊ុនថនៈ គាត់សួរអីខ្លះពូកាលហ្នឹង?

ហមៈ សួរយើងពាក់ព័ន្ធអារឿងក្បត់ហ្នឹងជាមួយអ្នកណាជាមួយពីណាអីហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហមៈ គេសួរយើងហើយយើងមាននៅជាមួយពីណា នៅជាមួយបងហ៊ានទ័ពស្រុកហ្នឹងឯង ។

ប៊ុនថនៈ ទ័ពស្រុកសៀមរាបហ្នឹង?

ហមៈ បាទ! ស្រុកពួកហ្នឹង ទៅដល់នោះមានបញ្ហាចេះចុះទៅគេហៅយើងទៅធ្វើប្រវត្តិរូបទៅ ។

ប៊ុនថនៈ បញ្ហាយ៉ាងម៉េចវិញ?

ហមៈ បញ្ហាថាយើងក្បត់យើងអីហ្នឹង យើងវាមិនដឹងណាយើងមានក្បត់អីណា យើងអត់ដឹង ។

ប៊ុនថនៈ ចុះមេពូនៅសៀមរាបហ្នឹង?

ហមៈ គាត់មានដឹងអីអត់ ។

ប៊ុនថនៈ បាទ ។

ហមៈ បើគេដកយើងចេញមកនេះអស់ហើយហ្នឹង ។

ប៊ុនថនៈ ពូអត់មានបានដឹងដំណឹងទេ?

ហមៈ អត់ អត់មានបានដឹងទេ ។

ប៊ុនថនៈ ចឹងមានសួរពូយូរទេ?

ហមៈ យី! មើលតាំងពីឆ្នាំ៧៧-៧៨ហ្នឹងណាស់ ។

ប៊ុនថនៈ តែនិយាយថា ហៅពូទៅសួរហ្នឹងប្រើរយៈពេលយូរទេ?

ហមៈ យូរដែលប្រហែលជា១០នាទីអី២០នាទីអីដឹង ទំរាំយើងហ៊ានឆ្លើយក្រដាសប៉ុននេះក្រដាសគេឡើងវែង ។

ប៊ុនថនៈ ក្រដាស?

ហមៈ ក្រដាសគេមួយសន្លឹកសរសេរឲ្យយើង គេសួរយើងឲ្យស្មោះត្រង់ជាមួយបក្ស យើងដឹងស្មោះត្រង់អីណាមិនដឹងបក្សណាផង ចេះតែថាអឺៗគេទៅឲ្យតែរួចខ្លួន ។

ប៊ុនថន៖ បាទ ។

ហម៖ គេសម្ងុតមែនទែនណាស់ ក្នាគេមានបីនាក់គេយាមពីក្រោយ គេថាឯងឆ្លើយមិនត្រង់ខ្សែភ្លើងឆក់ឥឡូវហើយ ។

ប៊ុនថន៖ ពូមានភ័យទេ?

ហម៖ និយាយយំតែម្ដង ។

ប៊ុនថន៖ ចឹងពូយំ?

ហម៖ យំ ចុះបើគេដកអាធីងទៅផ្សេង អាចាប់ទៅផ្សេងគេធ្វើម្នាក់មួយៗ ។

ប៊ុនថន៖ ហ្នឹងនៅកងជាមួយពូដែរ?

ហម៖ នៅជាមួយគ្នា ។

ប៊ុនថន៖ តែដកចេញបែកគ្នា?

ហម៖ បាទ!គេធ្វើម្នាក់មួយៗម្ដង ។

ប៊ុនថន៖ ចឹងបន្ទាប់ពីសួរហើយគេឲ្យពូ?

ហម៖ គេឲ្យមកវិញ មកចូលនេះវិញ បើយើងមិនស្មោះត្រង់គេ គេដកចេញ ។

ប៊ុនថន៖ ចុះមិត្តភក្តិពូ?

ហម៖ មិត្តភក្តិនោះមានណាគេជួយស្ងាត់មាត់ឈឹង ។

ប៊ុនថន៖ បាត់រហូតអីពូ?

ហម៖ ទេ មិត្តភក្តិដែលស្គាល់គ្នានោះមានពីណាហ៊ានតវ៉ា អាបូនេះមកអាឈើត្រង់នេះស្គាល់គ្នាហ្នឹង ។

ប៊ុនថន៖ តែអ្នកដែលហៅទៅសួរមានឈ្មោះ ធីង ឈ្មោះ ចិត្តអីនោះ?

ហម៖ អរ!បែកគ្នាហើយអានោះនៅកំពង់ធំ គេចាត់ទៅកំពង់ចាម ។

ប៊ុនថន៖ គេដកទៅហ្នឹងវិញ?

ហម៖ បែកគ្នាមិនដឹងជាគេទៅណាទេ ។

ប៊ុនថន៖ តែគេហៅមកសួរហើយហ្នឹងគេឲ្យមកវិញ?

ហម៖ បាទ!មកជុំគ្នាវិញ អាធីងហ្នឹងគេសួរធ្លាប់ហាត់ប៊ុន្នានដង ធ្លាប់វៃប៊ុន្នានដង គេឲ្យលូនលើផ្ទះនោះ អាផ្ទះដែលធ្លាប់ដេកនោះ ។

ប៊ុនថន៖ បាទ!គេសួរនៅហ្នឹង?

ហម៖ បាទ!កាលហ្នឹងប្រកែកជាមួយគេ គេយកទៅនោះ ខ្ញុំវាចេះទេ គេថាខ្ញុំហ្នឹងរឹងជាមួយគេ ខ្ញុំចូលដីទៅ ដីហុយទៅគេដើរចេញទៅ ខ្ញុំថាបើគ្រាន់បើដើរគេចចេញធ្វើអី ។

ប៊ុនថន: ចឹងប្រកែកជាមួយគេ?

ហម: បាទ!ដល់ចឹងគេធ្វើបាបខ្ញុំ ។

ប៊ុនថន: ប្រកែកជាមួយអ្នកធ្វើការក្នុងកងហ្នឹង?

ហម: ជាមួយ តា ម៉ុលហ្នឹងគេអ្នកគ្រប់គ្រងនោះ ខ្ញុំរកវ៉ៃ ។

ប៊ុនថន: ចឹងពូរកវ៉ៃ?

ហម: ហ្នឹងហើយ ចុះនៅកន្លែងចិនមានធម្មតាអីធាត់ជង ។

ប៊ុនថន: បាទ ។

ហម: យី!វ៉ៃមែនហ្នឹងឯង ។

ប៊ុនថន: ប្រកែកជាមួយគាត់?

ហម: ហ្នឹងហើយប្រកែកជាមួយ តា ម៉ុល ហ្នឹងឯង ដល់ហើយតា ម៉ុល គាត់ពន្យល់ខ្ញុំថា ប្អូនឯងបើពូកែកំពង់ពេញវ័យ អក្ខរគេវែងយកតែអក្ខរដើមទេ ឥឡូវហ្នឹង គេពន្យល់ខ្ញុំណែនាំខ្ញុំយូរណាស់ ខ្ញុំអត់ស្តាប់ ។

ប៊ុនថន: អត់ស្តាប់?

ហម: បាទ! រញ៉េរញ៉ៃដងប៉ែលទាញញើងញាំងៗ រកវ៉ៃដល់ហើយគេខឹងគេ គេហៅទៅធ្វើការលុតបណ្តោយ ។

ប៊ុនថន: ចឹងគាត់មិនឲ្យពូចូកដី?

ហម: ខ្ញុំចូកដីដាក់រម៉ក់គេនោះ នៅពីក្រោមកំពង់តែនាំខ្ញុំនោះដល់ហុយទៅលើគេគេចខ្ញុំថាឲ្យបណ្តោយ ដល់នេះសួរអាបូនេះបានដឹង ។

ប៊ុនថន: ចឹងគាត់គុំពូ?

ហម: បាទ!គាត់គុំខ្ញុំ ហើយពួកអាបូនេះស្មានថាងាប់ហើយ គេថាខ្ញុំងាប់បាត់ហើយចុះគេយកទៅហើយ ។

ប៊ុនថន: ចឹងនៅជុំគ្នាដែរ?

ហម: នៅជុំគ្នា ដល់ទៅមកៗគេដកខ្ញុំទៅរោងចក្រកែវវិញមួយសារទៀត ខ្ញុំទៅរោងចក្រកែវពីរសារនោះណាស់ ទៅពីរដងដល់ទៅដល់គណៈមន្ទីរគេសួរខ្ញុំយ៉ាងម៉េចបានមកវិញ ខ្ញុំថាគេដកខ្ញុំមក ដល់នេះគាត់ឲ្យខ្ញុំទៅភ្ជួរទៅ,

ប៊ុនថន: ទៅភ្ជួរនៅណា?

ហម: ទៅភ្ជួរទៅកន្ទួតទៅស្ទែងជ័យឧត្តមនោះ ជួបប្រពន្ធខ្ញុំនេះ ។

ប៊ុនថន: ចឹងជួបប្រពន្ធពូនៅហ្នឹង?

ហមៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងប្រពន្ធពូគាត់ធ្វើអីដែរ?

ហមៈ ទេ កាលនោះនៅក្មេងដែលហ្នឹង គេទៅស្ទូងដែលហ្នឹង ។

ប៊ុនថនៈ គេដកមកបន្ទាប់ពីសួរពូកាលនៅក្រសួង៨៧០ជាមួយចិនបានរយៈពេលប៉ុន្មានបានដកពូ ទៅរោងចក្រកែវវិញ?

ហមៈ ពីរឆ្នាំ ។

ប៊ុនថនៈ ចឹងពីរឆ្នាំបានដកទៅទៀត?

ហមៈ ពីរឆ្នាំដកទៅវិញទៀត ។

ប៊ុនថនៈ យ៉ាងម៉េចបានគេដកពូ ពូធ្វើខុស?

ហមៈ អាហ្នឹងមានបញ្ហាហើយ គេធ្វើប្រវត្តិរូបហើយគេដកទៅ ក្រសួង៨៧០ដើងខ្លាំងកន្លែងហ្នឹងហ៊ានមាត់ដឹងថាទៅហើយសើច...តែសារ៉ែនគេតៗហើយខ្ញុំភ័យណាស់ គ្រាន់តែឮសារ៉ែនខ្ញុំញ័រសាច់ ។

ប៊ុនថនៈ ឡានសារ៉ែន?

ហមៈ ឡានមកយក ។

ប៊ុនថនៈ មកយកហ្នឹងគេអត់មានចាប់អីទេ ហៅទៅតែម្តង?

ហមៈ គេបោយដៃ ចុះគេស្គាល់ស្រេច ។

ប៊ុនថនៈ បាទ ។

ហមៈ យើងកំពង់តែជីកប្រឡាយ គេហៅមកឡើងវ៉ៃទៅបាត់ ។

ប៊ុនថនៈ តែចង់សួរបន្តិច ប្រឡូក្នាបន្តិចដូចថា តា ម៉ុលហៅពូទៅសួរហើយគាត់ឲ្យមកមន្ទីរហើយ?

ហមៈ គាត់ឲ្យមកវិញ ។

ប៊ុនថនៈ បាទ ។

ហមៈ មកវិញបានដកទៅរោងចក្រកែវមួយសារ ។

ប៊ុនថនៈ ដកទៅរោងចក្រកែវ?

ហមៈ បាទ! ទៅមុនមានបញ្ហាដល់លើកក្រោយនេះមកគេមានទុកចិត្តយើងទេ គេដកទៅមួយសារទៀត មន្ទីរគេសួរបណ្តោយម៉េចបានជាមកវិញ ខ្ញុំថាគេឲ្យមក ។

ប៊ុនថនៈ ចឹងដកក្រោយហ្នឹងពូអត់មានរឿងទេ?

ហមៈ ដកក្រោយហ្នឹងហើយដែលមានរឿងហ្នឹងដកទៅហ្នឹងនោះ ។

ប៊ុនថនៈ ចឹងដែលពូរកវ៉ៃនោះ រកវ៉ៃតា ម៉ុលនោះ?

ហមៈ ហ្នឹងហើយ គេដកទៅកន្លែងតា គីរីញ កន្លែងខ្លាំងណាស់អាកន្លែងហ្នឹង ។

ប៊ុនថនៈ បាទ ។

ហមៈ កន្លែងលុតដុំថាស៊ីនំប៉័ងព្រឹកល្ងាច បបរខ្លះអីទៅ ។

ប៊ុនថនៈ បាទ ។

ហមៈ ទៅពីរសារណា ទៅមុនដំបូងអត់មានបញ្ហាទេ ទៅពីសៀមរាបទៅនោះមុន ។

ប៊ុនថនៈ បាទ ។

ហមៈ ទៅនោះហើយបានមកទូតចិន ដល់មានបញ្ហានៅទូតចិនបានគេដកទៅនោះវិញ ។

ប៊ុនថនៈ ទៅរោងចក្រកែវ?

ហមៈ បាទ ។

ប៊ុនថនៈ ចឹងពូនៅជាមួយតា គីហ្នឹងទៅភ្ជួរ?

ហមៈ ទៅភ្ជួរដីភ្ជួរអីទៅ កាប់ត្រែងកាប់អីពេញហ្នឹង ត្រពាំងក្រឡឹងហ្នឹងជីកដីដាំដូវរទេះភ្លើងគេហ្នឹង កាប់បន្លឺរែកខ្ជួនឯង ។

ប៊ុនថនៈ ដកតែពូឬដកអ្នកផ្សេងដែរ?

ហមៈ ដកគ្នាច្រើនណាស់ ដកគ្រប់តែគ្នាទៅដល់កំពង់សោមនោះ ដល់រត់កំពង់សោមមួយសារទៀតបានចូលខ្មែរក្រហម ។

ប៊ុនថនៈ ចឹងកាលទៅវត្តជ័យឧត្តមហ្នឹងតា ម៉ុលគាត់ទៅដែរ?

ហមៈ អត់ទេ អើតា ម៉ុលនៅជ័យឧត្តមដែលជួប ជួបជីកប្រឡាយហ្នឹង ។

ប៊ុនថនៈ ពូនៅកងជាមួយពីណាវិញកាលហ្នឹង?

ហមៈ នៅកងតា គីហ្នឹងឯង ។

ប៊ុនថនៈ ចុះតា ម៉ុលហ្នឹងគាត់នៅកងអីវិញ?

ហមៈ តា ម៉ុលហ្នឹងគាត់ទៅពីភ្នំពេញហ្នឹងឯង ទៅពីទូតចិនបានតែបន្តិចហ្នឹង ។

ប៊ុនថនៈ គេដកទៅឬយ៉ាងម៉េច?

ហមៈ គេដកទៅក្រោយខ្ញុំ ។

ប៊ុនថនៈ គេដកទៅក្រោយ?

ហមៈ ទៅហ្នឹងទៅកន្លែងលុតដុំគេហ្នឹង ។

ប៊ុនថនៈ ចឹងតា ម៉ុលហ្នឹងយ៉ាងម៉េចបានជាគេដកចេញ?

ហមៈ មិនដឹងទេ ។

ប៊ុនថនៈ ចឹងមានបាននិយាយជាមួយគាត់ទេ?

ហមៈ		អត់ទេ  មានបាននិយាយផង ។

ប៊ុនថនៈ	ចឹងគ្រាន់តែឃើញ?

ហមៈ		បាទ! ឃើញអត់និយាយរកគ្នាទេ ។

ប៊ុនថនៈ	ដកទៅហ្នឹងដកតែតា  ម៉ុលម្នាក់ឬមួយមានអ្នកផ្សេងៗទៅដែរ?

ហមៈ		ឃើញទៅតែឯងទេ ។

ប៊ុនថនៈ	ចឹងកាលតា  ម៉ុលទៅពូនៅមានតែខឹងអីដែរ?

ហមៈ		ខឹង  និយាយមិនខឹងយ៉ាងម៉េចធ្វើបាបខ្ញុំ ។

ប៊ុនថនៈ	តែនៅកងផ្សេងគ្នាគ្រាន់តែឃើញ?

ហមៈ		កងផ្សេងគ្នាឃើញបានតែប៉ុន្មានថ្ងៃហ្នឹង  តា  ម៉ុលដឹសន្កត់ហ្នឹងគេសែងមកបណ្ដោយហ្នឹង ។

ប៊ុនថនៈ	ចឹងពូអត់ដែលដឹងថាគាត់ទៅណាទៀតទេ?

ហមៈ		អត់ដឹងទេ  មិនដឹងជាងាប់ឬរស់ផង ។

ប៊ុនថនៈ	ចឹងពូទៅហ្នឹងជួបគ្រួសារពូនៅហ្នឹងទៅ?

ហមៈ		ខ្ញុំជួបពីក្មេងហ្នឹង  អត់ស្គាល់ទេតែចំណាំមុខគ្នាសួរប្រពន្ធខ្ញុំទៅ ។

ប៊ុនថនៈ	ហើយមកហ្នឹងបានជួបគ្នានៅនេះ?

ហមៈ		នេះមកជួបនេះ  នៅខ្វាងាប់នេះ ។

ប៊ុនថនៈ	ចឹងពូចំណាំពីហ្នឹងមក?

ហមៈ		បាទ! ធ្លាប់ឃើញគ្នាកាលនៅវត្តជ័យឧត្តមភ្លើងឆេះព្រៃគេដុតស្រូវហ្នឹង ។

ប៊ុនថនៈ	ខាងណាដុតពូ?

ហមៈ		ដឹងពីណាដុតទេ  កាលហ្នឹងប្រពន្ធខ្ញុំទេ  ឆេះដុះដាក់ស្រូវហ្នឹង  ស្រីៗរត់ឡើងទីសើច...  ខ្ញុំដេកជិតស្ពាបជញ្ជាំងនោះ  កន្លែងម៉ុងចិននោះដេកមើលក្របីនោះ ។

ប៊ុនថនៈ	ឆេះច្រើនទេពូ?

ហមៈ		ឆេះច្រើនស្រូវឡើងខ្ទិចខ្ទីរអស់  គេចាប់មនុស្សឡើង  គេចាប់មនុស្សមិនដឹងជាយកទៅណាខ្លះ ។

ប៊ុនថនៈ	ចាប់អ្នកនៅហ្នឹងពូ?

ហមៈ		ចាប់អ្នកនៅហ្នឹង ។

ប៊ុនថនៈ	ចឹងគ្រួសារពូគាត់នៅហ្នឹងដែលគាត់អត់អី?

ហមៈ		អត់អីទេ  គេចាប់តែអ្នកដុតហ្នឹង ។

ប៊ុនថនៈ	គេចាប់ប្រុសៗឬមួយយ៉ាងម៉េច?

ហមៈ		គេចាប់តែស្រីៗ ។

ប៊ុនថនៈ	ចឹងពូនៅជិតហ្នឹងដែរ?

ហមៈ		ខ្ញុំនៅអីខាងផ្លូវជាតិខាងក្រោមនេះទេ ប្រពន្ធខ្ញុំបានដេកនៅហ្នឹង ។

ប៊ុនថនៈ	ចឹងពូនៅហ្នឹងរហូតដល់វៀតណាមចូល?

ហមៈ		កាលវៀតណាមចូលខ្ញុំមកនៅកំពង់សោម ។

ប៊ុនថនៈ	នៅកំពង់សោម?

ហមៈ		បាទ ។

ប៊ុនថនៈ	ពូនៅខាងកងអីវិញមកនៅកំពង់សោមហ្នឹង?

ហមៈ		ទេ នៅកងដឹកដីដឹកដាក់លូអីហ្នឹង ក្បែរផ្លូវរទេះភ្លើងហ្នឹង ខាងមាត់សមុទ្រហ្នឹង ។

ប៊ុនថនៈ	បាទ ។

ហមៈ		ជិតផ្ទះបីគេហ្នឹង ។

ប៊ុនថនៈ	ជិតផ្ទះបី?

ហមៈ		បាទ ។

ប៊ុនថនៈ	តែពូនៅក្រោមតា គឺដដែលឬមួយដូរ?

ហមៈ		អត់ទេ ទៅនៅហ្នឹងមិនដឹងថាពីណាគ្រប់គ្រងផង អត់ស្គាល់គេផង គេបញ្ជូនទៅពីភ្នំពេញទៅ គេយកឡានមកយក ។

ប៊ុនថនៈ	បាទ ។

ហមៈ		ទៅដល់គេធ្វើរោងឲ្យយើងដេក ស្រីៗមួយរោងធំ ប្រុសៗមួយរោងទៅអែបផ្លូវរទេះភ្លើងយើងហ្នឹង ។

ប៊ុនថនៈ	បាទ ។

ហមៈ		នៅហ្នឹងឯងភ្លឺឡើងមានបន្លឺរសម្រាប់ដឹកដីអីទៅ អាមាត់សមុទ្រហ្នឹង ។

ប៊ុនថនៈ	មាត់សមុទ្រហ្នឹង?

ហមៈ		បាទ!ដល់នេះស្រាប់តែយប់មួយហ្នឹងឃើញភ្លើងមកពីងៗ ថាគេបាញ់គ្នា ។

ប៊ុនថនៈ	បាទ ។

ហមៈ		ស្រាប់តែរែកបន្លឺររត់ទៅ គេថាយួនចូលមើលឃើញឡានមកបាញ់គ្នាប៉ុងៗត្រូវចង្កេះ ។

ប៊ុនថនៈ	ខាងណាបាញ់?

ហមៈ		ពួកយួនហ្នឹង ។

ប៊ុនថនៈ	ពួកយួនបាញ់ត្រូវចំចង្កេះ?

ហមៈ បាទ! បាញ់ដូសេត បាញ់អ្នករកត្រីនោះផងមាត់សមុទ្របាញ់អានោះត្រូវអៀវរត់ ។

ប៊ុនថនៈ បាទ ។

ហមៈ ខ្ញុំរត់ទៅកន្លែងរោងចក្រប្រេងកាតហ្នឹងឈរមើលចេះ ឃើញរថក្រោះវាចូលមក ។

ប៊ុនថនៈ បាទ ។

ហមៈ ឃើញរថក្រោះចូលទៅ ខ្ញុំថាចាំវាទៅហួសចាំយកខោអាវ គានោះថាហួសណាទៅហ្នឹងទៅមិនរួចទេ ឆាប់ទៅយកមកខ្ញុំក៏រត់ទៅយកខោអាវរត់ទៅក្រោយគេតាមផ្លូវរទេះភ្លើង ។

ប៊ុនថនៈ តាមផ្លូវរទេះភ្លើង?

ហមៈ បាទ! មកក្រោយគេ ។

ប៊ុនថនៈ រត់មួយកន្លែងពីដីកហ្នឹងរត់ទាំងអស់គ្នា?

ហមៈ រត់ទាំងអស់គ្នាតែម្តង មកឡើងភ្នំឡើងហ្នឹងអូសដូចជាភ្នំណាទេឡើងភ្នំតែម្តង មើលពេញមើលឃើញច្បាស់ចេះ ។

ប៊ុនថនៈ បាត! កាលហ្នឹងរត់គាត់ពិជនិលអីដែរ?

ហមៈ បាទ! ហ្នឹងហើយឡើងភ្នំហ្នឹង ។

ប៊ុនថនៈ កាលហ្នឹងមកច្រើនទេពូ?

ហមៈ មកលច្រើនមនុស្សរាប់ម៉ឺននាក់នោះ អាខ្លះកូនពេញតែលើភ្នំក៏មាន ទុកកូនចោលពេញតែព្រៃហ្នឹង ។

ប៊ុនថនៈ សម្រាលកូនពូ?

ហមៈ ហ្នឹងហើយកូនអាខ្លះស្លាយមិនអស់ក៏ចោលទៅ យំពេញហ្នឹង ខ្ញុំឡប់អស់ហើយមានបានអីទេ ។

ប៊ុនថនៈ រត់តែខ្លួនមួយ?

ហមៈ បាទ! ដល់រត់មកក៏ចូលត្រពាំងក្រឡឹងហ្នឹង លាក់កងជើងហ្នឹងមកជាប់នៅហ្នឹងឯង្ហនោះ ។

ប៊ុនថនៈ កំពង់ស្ពឺនេះ?

ហមៈ លាក់កងជើងហ្នឹង កំពង់ស្ពឺដីង ។

ប៊ុនថនៈ បាទ! កំពង់ស្ពឺ?

ហមៈ ហ្នឹងហើយជាប់ក្រោលគោហ្នឹងឯង ក្មេងៗយាមចូលក្នុងក្រោលគោហ្នឹងនៅហ្នឹងបណ្តោយហ្នឹង ។

ប៊ុនថនៈ បាទ ។

ហមៈ គេរកវ៉ៃចោលនៅកន្លែងហ្នឹងទៀត ។

ប៊ុនថន៖ រត់ចូលហ្នឹងចូលខាងណាវិញពូ?

ហម៖ ចូលខាងខ្មែរក្រហមហ្នឹង រត់ចូលហ្នឹងទៅគេដេញឲ្យចូលយើងកម្មករហ្នឹង មកពីនោះគេដេញឲ្យចូលហ្នឹង ។

ប៊ុនថន៖ បាទ ។

ហម៖ ខ្លះទៅអមលាំងទៅ ខ្ញុំមួយចំនួនក៏ចូលនៅកន្លែងហ្នឹងទៅ ទៅនៅហ្នឹងបណ្តោយគេមិនឲ្យចេញ ។

ប៊ុនថន៖ គេមិនឲ្យចេញទេ?

ហម៖ បាទ! ហើយគេយាមយប់ឡើងគេដើរយាមនៅហ្នឹងឯង ។

ប៊ុនថន៖ ច្រើននាក់ដែលពូ?

ហម៖ យី! ច្រើនណាស់ អាខ្លះគេបាញ់ផាប់ ។

ប៊ុនថន៖ ចុះយ៉ាងម៉េចបានបាញ់ហ្នឹង?

ហម៖ ដឹង ចុះយើងមានកាំភ្លើងឯណាកាលនោះ បាញ់ផាប់អាខ្លះរត់ទៅអន្គភាព ប្រពន្ធខ្ញុំមកអត់ហ៊ានរត់នៅរាប់រយនៅហ្នឹង គេប្រើកាំព្រៃស្អីគេទេ ព្រួញអីគេដាក់កាត់ផ្លូវ ។

ប៊ុនថន៖ ចំរូង?

ហម៖ ទេ មិនមែនចំរូងទេ គេបិទដូចកន្ទុយអន្ទង់ចឹង ធ្វើដូចជាអន្ទាក់ចឹងយើងដើរទៅទាក់រឹប ។

ប៊ុនថន៖ បាទ ។

ហម៖ ដល់នេះគេថាពួកឯងហ្នឹងអាពួកកន្សែងខៀវ ។

ប៊ុនថន៖ កន្សែងខៀវយ៉ាងម៉េចទៅ?

ហម៖ កន្សែងខៀវហ្នឹងមកពីភ្នំពេញហ្នឹង គេថាយើងស្រួល ។

ប៊ុនថន៖ បាទ ។

ហម៖ នៅតែថ្ងៃគេសម្លាប់ចោលតែដល់នេះ តា ម៉ុកទៅយក ។

ប៊ុនថន៖ តា ម៉ុកទៅយក?

ហម៖ ហ្នឹងហើយតា ម៉ុកទៅយកបានរស់កុំអីចប់ ។

ប៊ុនថន៖ ចឹងគាត់ទៅយកកម្មករនិងពូហ្នឹងយកមកទាំងអស់?

ហម៖ យកមកទាំងអស់ហ្នឹង តា ម៉ុកទៅយកទាំងអស់ ថាឯងនៅនេះមានអីស៊ីទេ ទៅនៅដីពាយ័ព្យបានមានស្រូវស៊ី តា ម៉ុកទៅយកហ៊ឹមកទាំងអស់គ្នាមក ។

ប៊ុនថន៖ ចុះអ្នកនៅហ្នឹង?

ហម៖ អ្នកនៅហ្នឹងផ្ទះគេនៅហ្នឹងនៅទៅ ។

ប៊ុនថន៖ បាទ ។

ហម៖ កម្មករមកទាំងអស់ ទៅយកមកទាំងអស់មកដីស្រែសាម៉ែនហ្នឹង ។

ប៊ុនថន៖ ស្រែសាម៉ែន?

ហម៖ បាទ! ស្រែសាម៉ែនហ្នឹង ។

ប៊ុនថន៖ ចឹងនៅលាក់កងជើងហ្នឹងមានពីណាគ្រប់គ្រងវិញ?

ហម៖ អូ! មិនដឹងជាពីណាគ្រប់គ្រងទេ មានមេមានកើយទេ រត់រប៉ាត់រប៉ាយ ។

ប៊ុនថន៖ ចឹងអ្នកយាមពួនោះ?

ហម៖ អ្នកយាមស្រុកគេហ្នឹង មានកាំភ្លើងមានស្នាគេដើរយាមយើង ហើយអាព្រួយបាញ់ឯង ហ្នឹងគេដាក់កាត់ផ្លូវចេះ ។

ប៊ុនថន៖ តែមិនដឹងថាពីណាគ្រប់គ្រងទេ?

ហម៖ មិនពីណាគ្រប់គ្រងទេ រកមេលែងឃើញហើយ ។

ប៊ុនថន៖ បាទ ។

ហម៖ អត់មានមេណាទេ ។

ប៊ុនថន៖ ចុះកាលតា ម៉ុកទៅយកហ្នឹងមានគ្នាច្រើនទេទៅ?

ហម៖ តា ម៉ុកឡានគាត់ ឡានអាស្រ៊ីបគាត់ហ្នឹង ។

ប៊ុនថន៖ ចឹងមានកងទ័ពទៅជាមួយទេ?

ហម៖ មានកងទ័ពគាត់ទៅយកប្រកាសណាកម្មករយកមកទាំងអស់ ។

ប៊ុនថន៖ ចឹងអ្នកយាមដែលនៅហ្នឹងអត់មានឃាត់ទុកទេ?

ហម៖ អត់ទេ ពីណាហ៊ានជាមួយតា ម៉ុក ។

ប៊ុនថន៖ បាទ ។

ហម៖ តា ម៉ុកយកមកដើរមកតាំងពីលាចអីនោះ រុកព្រៃសំម៉ើមណាស់ជិតផាប់ទៀត បានធ្លាក់មកស្រែសាម៉ែនយើងនេះ ធ្លាក់ស្រែសាម៉ែននេះយួនដេញបាញ់មួយសារទៀត ។

ប៊ុនថន៖ និយាយថាមកហ្នឹងជិះឡានរហូតឬមួយដើរមក?

ហម៖ អត់ទេ ដើរមកតាមព្រៃ ។

ប៊ុនថន៖ គាត់នាំមក?

ហម៖ ដឹងថាពីណានាំមកចេះតែតាមគ្នាទៅ ។

ប៊ុនថន៖ បាទ ។

ហមៈ	មកតាំងពីលាចរហូតចេះតែមកទៅ មានអង្ករគេចែកឲ្យយើង តម្រង់ផ្លូវគេចែកអង្ករឲ្យដល់“កាហត”ហ្នឹងយួនទាន់មួយសារទៀត រត់រួចទៀត ។

ប៊ុនថនៈ	កាហតនៅណាវិញ?

ហមៈ	កាហតព្រៃម្ទេសនេះដីបាត់ដំបងនេះ ខេត្តបាត់ដំបងនេះ ។

ប៊ុនថនៈ	បាទ ។

ហមៈ	ស្រីៗកំពង់តែរកចៃយួនមកទាន់ចាប់យកអស់រលីងទៅ មីងខ្ញុំទៅស្រុកទៅ ។

ប៊ុនថនៈ	យកទៅវិញ?

ហមៈ	បាទ!យកទៅស្រុកវិញ ប្រុសៗចាប់អត់បានរត់ទៅទៀតសើច...រត់កាត់ស្រែសាម៉ននេះ ។

ប៊ុនថនៈ	ស្រែសាម៉នហ្នឹងនៅណាវិញ?

ហមៈ	នៅនេះ នៅខេត្តយើងនេះឯង ។

ប៊ុនថនៈ	នៅខេត្តបន្ទាយមានជ័យ?

ហមៈ	ហ្នឹងហើយ ខេត្តបាត់ដំបងមិនដឹងព្រំប្រទល់ហើយកាលនោះ ព្រំប្រទល់ទេ ខេត្តបាត់ដំបងទើបកើតចេញមកខេត្តបន្ទាយមានជ័យនេះ ។

ប៊ុនថនៈ	បាទ ។

ហមៈ	មកនៅហ្នឹងហើយយាមៗសំបកក្នុងហ្នឹងយួនមកដេញបាញ់មួយសារទៀត ។

ប៊ុនថនៈ	មកដេញទាន់ទៀត?

ហមៈ	ដេញទាន់ទៀត បែកបាក់គ្នាខ្លាយនោះ មិនដឹងជាស្អីស្អុកទេ ។

ប៊ុនថនៈ	នៅសល់គ្នាច្រើនទេពូ?

ហមៈ	យី!សល់មនុស្សទាំងស្រីទាំងប្រុសរាប់ម៉ឺន ។

ប៊ុនថនៈ	រត់មកមានបែកគ្នាទៀតដែរ?

ហមៈ	រត់មកបែកគ្នាខ្លះគេសម្លាប់ចោលតាមផ្លូវទៅ ។

ប៊ុនថនៈ	ខាងណាសម្លាប់ពូ?

ហមៈ	មិនដឹងជាខាងណាទេ ខ្ញុំអត់យល់ដែរ ។

ប៊ុនថនៈ	បាទ ។

ហមៈ	ឲ្យតែគេមានកាំភ្លើងគេមើលមុខយើងចេះត្រូវហើយ ទាញដៃយកទៅ យើងចេះតែគេចៗចេះតែខ្ទិបគ្នាទៅអង្គរនៅទៃស្តាយទៅទឹកជងដូចថាគ្នាយើងប៉ុន្មាននាក់៥នាក់ ពួកខ្ញុំមកនៅបឹងបេងជាមួយអាជល្លីតាមគ្នាតែចឹង ។

ប៊ុនថន៖ បាទ ។

ហម៖ បានអាហ្នឹងហើយមកជួបគ្នាទៀត មកពីស្រុកជួបអាឈរនេះមួយ ។

ប៊ុនថន៖ បាទ ។

ហម៖ នៅទួតចិនបានអាបូនេះមួយ ។

ប៊ុនថន៖ ចឹងតា ម៉ុកយកមកហើយហ្នឹងនៅបែកគ្នាទៀត?

ហម៖ បែកគ្នាទៀត ចុះយួនដេញបាញ់ កម្មណាស់ ។

ប៊ុនថន៖ មកនៅស្រែសាម៉នហ្នឹងបានយូរទេ?

ហម៖ ម៉េចបានយូរបានតែប៉ុន្មានយប់ហ្នឹងយួនដាក់ប្រ៉ាវ កាប់គោស៊ីមិនបានស៊ីផង ។

ប៊ុនថន៖ អត់មានអីកាប់គោហូប?

ហម៖ កាប់គោ ចុះគោដែលប្រជាជនរត់ចោលទៅ កាប់គោស៊ីមិនបានស៊ីផង ។

ប៊ុនថន៖ ចឹងរត់ចេញមកទៀត?

ហម៖ រត់ចេញមកទៀត ។

ប៊ុនថន៖ ចឹងរត់ចេញពីស្រែសាម៉នហ្នឹងទៅណាវិញ?

ហម៖ ចេញពីស្រែសាម៉នទៅមិនដឹងជាទៅណាទេ យី! ចេញមកធ្វើទាហានបណ្តោយ ។

ប៊ុនថន៖ ចឹងចេញពីហ្នឹងមកធ្វើទាហាន?

ហម៖ ចេញពីហ្នឹងមកធ្វើខ្មែរក្រហមហ្នឹង ចូលខ្មែរក្រហមទៅ ។

ប៊ុនថន៖ ធ្វើនៅណាវិញទៅ?

ហម៖ ធ្វើនៅ៣២នោះ នៅលើដី៣២នោះ ។

ប៊ុនថន៖ ដី៣២នៅណាវិញ?

ហម៖ នៅដីខេត្តបាត់ដំបង ។

ប៊ុនថន៖ នៅដីសាស់ស្តាសំពៅលូនហ្នឹង?

ហម៖ ហ្នឹងហើយខ្ញុំទៅយាម....ដើរបាញ់តែស្វាស៊ីហ្នឹង ។

ប៊ុនថន៖ បាទ ។

ហម៖ ទៅយាមយូរៗចាញ់បោកខ្មែរសេរីយ៉ាងម៉េចទៅ គេដកមក៤៥០នេះមកគីឡូ៩ យើងនេះ ។

ប៊ុនថន៖ គីឡូ៩?

ហម៖ បាទ ។

ប៊ុនថន៖ ឆ្នាំណាគេដកពួកទៅ?

ហមៈ ទេ មិនដឹងជាឆ្នាំប៉ុន្មានទេ ។

ប៊ុនថនៈ កាលហ្នឹងបានយូរទេពូ?

ហមៈ បានយូរដែលហ្នឹង ពេញអត់បាយហ្នឹងបាញ់តែស្វាស៊ីទៅ ។

ប៊ុនថនៈ ច្រើនទេពូ ទៅ៣២ហ្នឹង?

ហមៈ យី!ទាហានមិនចេះតិច ។

ប៊ុនថនៈ កាលនៅហ្នឹងពូនៅខាងណា?

ហមៈ នៅខាងតា ឈ្មោះអីទេ គាត់ទៅណាបាត់ហើយពួកខ្ញុំនៅដែលតើ ពួកអាអុនអីហ្នឹងបានគេស្គាល់ ខ្ញុំទៅក្រោយគេ គេកងចាស់ ។

ប៊ុនថនៈ យើងទៅថ្មី?

ហមៈ យើងទៅថ្មី ដល់តាហ្នឹងចាញ់បោកខាងខ្មែរសេរីទៅ គេថាខ្មែរសេរីចាញ់បោកគេទៅដល់ចឹងគេដកយោធាទាំងអស់មក៨៥០នេះ ៧៩នេះ ។

ប៊ុនថនៈ ឆ្នាំ៧៩?

ហមៈ បាទ ។

ប៊ុនថនៈ ចឹងពូមក៨៥០នេះ?

ហមៈ បាទ!របូតទាល់តែឥឡូវ ។

ប៊ុនថនៈ ៨៥០ហ្នឹងខាងណា?

ហមៈ ខាងបង ភាពយើងនេះ ។

ប៊ុនថនៈ ចឹងសុខ ភាពគាត់គ្រប់គ្រង?

ហមៈ ហ្នឹងហើយ តា នឿនយើងនេះ ។

ប៊ុនថនៈ គាត់ឈ្មោះអីនឿន ឈ្មោះពេញ?

ហមៈ មិនដឹងជាឈ្មោះអីទេ នាមត្រកូលគាត់នឿន សួរប្អូនថ្ងៃគាត់បានដឹងតា នឿន ។

ប៊ុនថនៈ ផ្ទះគាត់ខាងមុនហ្នឹង?

ហមៈ នោះកន្លែងពេទ្យហ្នឹង ។

ប៊ុនថនៈ បាទ ។

ហមៈ ហ្នឹងបានស្គាល់តា នឿនយើងហ្នឹង គាត់កាត់ហើយគាត់របួស ខ្ញុំមកនៅជាមួយគាត់យូរហើយ ។

ប៊ុនថនៈ បងគាត់កំពង់តែសួរ ។

ហមៈ ហ្នឹងហើយ ខ្ញុំនៅជាមួយគាត់យូរហើយពុលទឹកពុលអី ពុលនៅកងពលតា ផុន ។

ប៊ុនថន៖ ពុលយ៉ាងម៉េចវិញពូ?

ហម៖ ពុលទឹកអាស៊ីតដែលគេយកទៅទុកយូរនោះណាស់ យើងផឹកអណ្តូងផឹកចាំវៃយូននោះ ។

ប៊ុនថន៖ បាទ ។

ហម៖ មកផឹកទៅពុលស្លាប់មនុស្សឡើង ខ្ញុំរិសស្លាប់ដែលហ្នឹង ឥឡូវវាហាំរៃរាល់ថ្ងៃ ។

ប៊ុនថន៖ ហូបទឹកហ្នឹងមានជាតិអាស៊ីតឬមួយយ៉ាងម៉េច?

ហម៖ មានជាតិអាស៊ីតហ្នឹងឯង ពាងវាឡើងប៉ុណ្ណណឹ ពួកហ្នឹងទៅកាប់ចំការឃើញពាងប៉ុណ្ណណឹ ដល់យើងផឹកទៅឃើញគ្រាៗតែយើងអត់ទឹកចេះតែផឹក ដល់ស្លាប់មនុស្សមិនចេះតិច ។

ប៊ុនថន៖ ឃើញស្លាប់ភ្លាមៗតែម្តង?

ហម៖ បាទ!គ្រាន់តែគ្រឹបទៅៗបណ្តោយ ខ្ញុំសន្ទប់ដែលហ្នឹង ។

ប៊ុនថន៖ បាទ ។

ហម៖ គេដាក់សេរ៉ូមឲ្យទៅបានមក ។

ប៊ុនថន៖ ចឹង៣២ហ្នឹងពូដកមក មកនៅម៉ាឡៃនេះ?

ហម៖ បាទ!មកនៅម៉ាឡៃនេះដំបូង ។

ប៊ុនថន៖ នៅកន្លែងណាម៉ាឡៃ?

ហម៖ នៅនោះនៅបឹងបេងនោះ ស្ពានយោលៗនោះមានដែលស្គាល់ទេ ។

ប៊ុនថន៖ មិនដែលស្គាល់ទេ ។

ហម៖ ឥឡូវគេចែកព្រំប្រទល់គ្នាហើយ ខ្ញុំនៅហ្នឹងឯងដាក់មីនហ្នឹងរៃទាហានតាមហ្នឹងព្រៃនេះ ។

ប៊ុនថន៖ បាទ ។

ហម៖ បានគេដកកាត់ស្រះខ្មែរសេរីនេះ ទៅនៅខ្វាស្លាប់ទៅបានៗប្រពន្ធខ្ញុំរាល់ថ្ងៃនេះ គេមិនចង់ឲ្យយកជនហ្នឹង គេចង់ចាប់ដាក់គុកទៀតនោះ ។

ប៊ុនថន៖ យ៉ាងម៉េចបានជាគេចង់ចាប់ដាក់គុកពូ?

ហម៖ គេមិនចង់ឲ្យយើងយកប្រពន្ធទេ តែយកប្រពន្ធអត់មានពីណាទៅមុខទេ ។

ប៊ុនថន៖ ចឹងពូស្គាល់គាត់ចឹងពូស្នើរគេទៅលើឬមួយយ៉ាងម៉េច?

ហម៖ សុំគេទៅលើ គេឲ្យការឲ្យសែនដែលហ្នឹង ដល់នេះត្រឹមកងវរៈគេឲ្យសែនឲ្យការអីហ្នឹង ដល់តា នឿននេះគាត់អត់ដឹង គាត់អត់ដឹងតា ជឿងរាល់ថ្ងៃនេះ តា ជឿងគាត់ប្រុងដក ។

ប៊ុនថន៖ ចឹងគេនិយាយថាមិនចង់ឲ្យមានគ្រួសារតែម្តង?

ហម៖ បាទ!គេមិនចង់ឲ្យមានទេ មានអគ្គភាពខ្ញុំមួយអាវិតមួយដកទៅ ឥឡូវវាអត់អីផង ។

ប៊ុនថន៖ ដកទៅវិញដោយសារគាត់ចង់រៀបការ?

ហមៈ ហ្នឹងហើយគេដកមិនឲ្យធ្វើទាហាន គេដកមកដាក់មន្ទីរផ្សេងទៀត ។

ប៊ុនថនៈ ចឹងពូរាយការណ៍ទៅសាវឿននេះគេអត់ថាអីទេ?

ហមៈ គេអត់មានថាអីទេ មេកងអី តា ចននិងតា អេងនៅហ្នឹង តា ចនគាត់ងាប់ហើយធ្វើប៉ូលីសគេបាញ់ ដល់នេះទៅរាយការណ៍ទៅតា ជឿងទៅ គាត់មានរករឿងថាមិនឲ្យសែនអីណា អាហ្នឹងប្តូគាត់សែនឲ្យ ។

ប៊ុនថនៈ ប្តូណា?

ហមៈ ប្តូហ្នឹងគាត់ទៅវិញហើយ គាត់សែនឲ្យស្ងើច... ។

ប៊ុនថនៈ ចឹងគាត់សែនឲ្យចឹងខាងលើគាត់អត់មានថាអីទេ?

ហមៈ គាត់មានថាអីផង ។

ប៊ុនថនៈ ឬលួចលាក់មិនឲ្យដឹង?

ហមៈ ដឹងតើ តែគេមិនថាអី ដល់នេះទៅក៏រត់យួនបុកដេញកន្ទែងខ្លាំងាប់ទៅ រត់ទៅភ្នំខៀវទៀតទៅ ទៅទាំងអស់គ្នាហ្នឹង ខ្វះគេទៅដំរំទៅខ្ញុំទៅភ្នំខៀវទៅ ទៅកន្ទែងតា ឈាន ។

ប៊ុនថនៈ អ៊ុំ ឈាន?

ហមៈ បាទ ។

ប៊ុនថនៈ ភ្នំខៀវនៅណា?

ហមៈ ឆ្ងាយណាស់ ទៅធ្វើការទៅប្រជុំ....នៅអីណាភ្នំនោះ អ៊ុំ ឈាននៅប៉ៃលិន ។

ប៊ុនថនៈ បាទ!ចឹងភ្នំខៀវហ្នឹងនៅជិតប៉ៃលិនដែលឬយ៉ាងម៉េច?

ហមៈ មានជិតអីទេ ឆ្ងាយណាស់ ដើរឡើងហើមក្ដៅប៉ុននេះខ្ញុំហ្នឹង ឡើងដណ្ដើរ៥០០ទៅនៅហ្នឹងងាប់ជិតអស់បានមកវិញ បានមកនៅ៨៥ដីថៃនេះ បានកូនខ្ញុំអាបងហ្នឹង ។

ប៊ុនថនៈ ចឹងនៅពេលដែលកំលាំងវៀតណាមបុកហ្នឹងពូរត់ទៅហ្នឹងម្ដងទៀត?

ហមៈ រត់ទៅភ្នំខៀវ ប៉ៃលិនហ្នឹង ។

ប៊ុនថនៈ ឆ្នាំណាវៃបុកហ្នឹង?

ហមៈ ទេ មិនដឹងជាឆ្នាំណាទេ ភ្លេចឆ្នាំហើយ ។

ប៊ុនថនៈ ចឹងទៅហ្នឹងទៅទាំងគ្រួសារលោកពូដែរ?

ហមៈ ទៅទាំងអស់ ទៅនៅអូរតារស់ភ្នំខៀវហ្នឹងឯង តែមិនដល់ភ្នំខៀវទេនៅត្រឹមអូរតា រស់ខាងនោះចំការកៅស៊ូណាស់ ។

ប៊ុនថនៈ បាទ ។

ហមៈ បាននៅកណ្តាលព្រៃហ្នឹងទៅ ឈើឡើងអូស១១ ខ្ញុំមកវិញដឹកមកវិញដាក់ដីថៃ គេហៅ ៨៥ ១ដីថៃណាស់ ។

ប៊ុនថនៈ បាទ ។

ហមៈ សំរាលបានកូនខ្ញុំអានេះ អាបង ។

ប៊ុនថនៈ បាទ!ចឹងកាលពួរត់ទៅហ្នឹងស្លាប់ច្រើនដែរ?

ហមៈ យី! ។

ប៊ុនថនៈ ស្លាប់ដោយសារអីពូ?

ហមៈ ឈឺនិងអត់អីស៊ី ។

ប៊ុនថនៈ កងទ័ពហ្នឹងពូ?

ហមៈ បាទ!កងទ័ពហ្នឹងឈឺ តា ហុងយើងយកមក កងទ័ពរត់មកវិញ ។

ប៊ុនថនៈ តា ហុងណាវិញ?

ហមៈ តា ហុងកងពលយើងនេះ ។

ប៊ុនថនៈ គាត់ជាប្រធានកងពល?

ហមៈ ហ្នឹងហើយកងពលធំ ។

ប៊ុនថនៈ គាត់ទៅដែរ?

ហមៈ គាត់ទៅតើ ។

ប៊ុនថនៈ នាំទៅ?

ហមៈ បាទ ។

ប៊ុនថនៈ គាត់អត់អីទេ គាត់នៅរស់រាល់ថ្ងៃទេ?

ហមៈ នេះ គាត់នៅនេះនៅខាងកើតនេះ តាំងតា ទៀនអីទៅទាំងអស់មេកងពលអីនៅទាំងអស់ជុំគ្នានៅហ្នឹង កូនទាហានអីទៅទាំងអស់ ។

ប៊ុនថនៈ ទៅនៅបានយូរទេពូ?

ហមៈ ទៅយូរដែលហ្នឹងឯងនៅនេះយើងមានដីណា ។

ប៊ុនថនៈ បាទ ។

ហមៈ ឃ្លួនយកទាំងអស់ហ្នឹង មួយជួរនេះសុទ្ធតែឃ្លួនហើយនេះ ។

ប៊ុនថនៈ ទៅហ្នឹងហើយបានពូ?

ហមៈ ទៅនៅហ្នឹងហើយបានគេដកមកនៅ៨៥ហ្នឹង ចុះវៃជាមួយឃ្លួនមួយសារទៀតវៃតាមហ្នឹង ហើយបានដីនៅនេះ ។

ប៊ុនថន៖ បាទ!ចឹងកាលដើមដំបូងហ្នឹងពូនៅបឹងបេង?

ហម៖ នៅបឹងបេង ។

ប៊ុនថន៖ តែនៅម៉ាខ្សែនេះមានផ្ទះមានអីហើយនៅពូ?

ហម៖ មិនមានទេ ។

ប៊ុនថន៖ ចឹងផ្លូវអីសុទ្ធតែព្រៃ?

ហម៖ សុទ្ធតែព្រៃ ។

ប៊ុនថន៖ ចឹងព្រៃក្រាស?

ហម៖ កាលហ្នឹងប្រជាជននៅម្តងហើយ ដីខាងមាត់អូរណាស់ ។

ប៊ុនថន៖ បាទ ។

ហម៖ ដល់យួនបុកទៅរត់ទាំងអស់គ្នានៅជំរំ ខ្លះទៅជំរំខ្ញុំទៅភ្នំខៀវទៅមកវិញព្រៃញុំកសុទ្ធតែរបងលួសមីននាប់ហើយ ។

ប៊ុនថន៖ និយាយថាពូមកនៅដំបូងហ្នឹងមកនៅបឹងបេងមែនទេ?

ហម៖ បាទ!បឹងបេង គេហៅនេះគ្រាប់ណាស់ គេដុតគ្រាប់កាលហ្នឹង ។

ប៊ុនថន៖ បឹងបេងហ្នឹង កាលពូមកមានគ្នាច្រើនទេ?

ហម៖ យី!កងទ័ពដែលតិច ។

ប៊ុនថន៖ ចឹងមកដល់ដំបូងហ្នឹងស្ថានភាពនៅម៉ាខ្សែហ្នឹងមិនមានការកកើតផ្ទះសំបែងអី?

ហម៖ អត់ទេ ផ្ទះអត់មានទេសុទ្ធព្រៃ ។

ប៊ុនថន៖ ព្រៃទាំងអស់?

ហម៖ ព្រៃ ។

ប៊ុនថន៖ ពួកគេថាមានសត្វមានអីទៀតពូ?

ហម៖ សត្វយកទៅណាអស់ និយាយពីរឿងសត្វខ្ញុំប្រាប់ទៅឡើងច្រើន ដាក់តែអន្ទាក់យកទៅណាអស់ ។

ប៊ុនថន៖ ចឹងកាលពូមកដល់ដំបូងមានគ្រាប់មីនមានអីទេ?

ហម៖ មាន ។

ប៊ុនថន៖ ពូមកពីភ្នំខៀវ?

ហម៖ ហ្នឹងហើយពីភ្នំខៀវ ។

ប៊ុនថន៖ ដកពីសាស់ស្តាមកនេះហ្នឹង?

ហម៖ និយាយពីភ្នំខៀវមក មកនៅ៨៥ហ្នឹងដីថៃ គេហៅ៨៥ណាស់ ។

ប៊ុនថន: បាទ ។

ហម: ហ្នឹងហើយ យើងចុះវ៉ៃនេះហ្នឹង ដោះមីនបណ្ដើរៗ វ៉ៃទាហានខ្មែរតាមនេះ ។

ប៊ុនថន: ចឹងកាលពូនៅចឹងបេងមិនទាន់មានគ្រាប់មីនទេ?

ហម: មាន ។

ប៊ុនថន: មានគ្រាប់មីនរួចហើយ?

ហម: មានពេញតែដីនេះហើយ ។

ប៊ុនថន: ចឹងមានដឹងខាងណាគេដាក់ពូ?

ហម: ខាងក្នុងក៏ដាក់ យើងក៏ដាក់ ដាក់ដូចគ្នាហ្នឹង ។

ប៊ុនថន: បាទ ។

ហម: ចំរុះ ។

ប៊ុនថន: ចឹងមកដល់ប៉ឹងបេងហ្នឹងមានរួចហើយ?

ហម: មានរួចហើយ គេដាក់យូរហើយ ។

ប៊ុនថន: ច្រើនទេ កាលមកដល់ដំបូង?

ហម: ច្រើនណាស់ បើនិយាយរឿងមីន គ្រាន់តែយួនដាក់ពីមាត់អូរខាងនេះហ្នឹងមិនតិចខ្សែទេ មីនក្ដាមីនទាក់សព្វគ្រប់ អាមីនយើងផង ។

ប៊ុនថន: បាទ ។

ហម: ដាក់លាយគ្នា ។

ប៊ុនថន: ពូមកពីភ្នំខៀវទៅ៨៥កាលឆ្នាំណា?

ហម: ទេមិនដឹងជាឆ្នាំណាទេ មិនដឹងជាឆ្នាំណាទេមិនសូវបានគិតផង សួរប្រពន្ធខ្ញុំបានដឹង ។

ប៊ុនថន: បាទ ។

ហម: មើលតាំងពីកូនខ្ញុំកើតឡើង ឥឡូវវា២០ប៉ុន្មានហើយ២៤ហើយ ។

ប៊ុនថន: ចឹងទៅនៅ៨៥ហ្នឹងគ្រួសារលោកពូទៅនៅហ្នឹងដែរ?

ហម: បាទ! ទៅនៅហ្នឹងដែរ នៅ៨៥ហ្នឹងខ្ញុំចុះមកប្រចាំសមរភូមិល្ហាសៀ ។

ប៊ុនថន: ល្ហាសៀ?

ហម: បាទ ។

ប៊ុនថន: ចឹងគ្រួសារពូនៅក្រោយ?

ហម: នៅក្រោយ៨៥ហ្នឹង បើកអង្គរអីនៅហ្នឹង ។

ប៊ុនថន: ចឹងមកនៅនេះតែម្ដងឆ្នាំណា?

ហមៈ ឆ្នាំណាឯងមកនៅនេះកំណើតអាហ៊ីងហ្នឹង មកនៅឆ្នាំ៩០ ។

ប៊ុនថនៈ ៩០?

ហមៈ ៩០-៩១ហ្នឹងឯង អាហ៊ីងកើតឆ្នាំណា ៩០-៩១ហ្នឹង ។

ប៊ុនថនៈ បាទ ។

ហមៈ កូនខ្ញុំបាននៅនោះពីរអាបងមួយនិងអានេះមួយ ។

ប៊ុនថនៈ បាទ ។

ហមៈ មកនេះកើតបានតែមួយឯង ។

ប៊ុនថនៈ កាលមកនៅដំបូងគេបែងចែកយ៉ាងម៉េចទៅពូ ដូចថាដីធ្លីអីចឹងពូ?

ហមៈ អត់មានពីណាបែងចែកទេ ចាប់នៅរៀងខ្លួនតែម្តង ។

ប៊ុនថនៈ អ្នកណាចាប់បានប៉ុន្មានយកប៉ុណ្ណឹងទៅ?

ហមៈ ហ្នឹងហើយ ពីណាបានប៉ុន្មានយកប៉ុណ្ណឹងទៅ ខ្ញុំនៅមាត់អូរនោះដីតូចមួយសើច...មានពីណាគេធ្វើផ្ទះឲ្យខ្ញុំនៅមុខនោះ ។

ប៊ុនថនៈ បាទ ។

ហមៈ មកដល់ផ្ទះ កូនផ្ទះខ្ញុំតូចត្រូលកូនខ្ញុំពីរនាក់សើច...ប្រពន្ធខ្ញុំដើរស៊ីឈ្នួលគេ ។

ប៊ុនថនៈ ចឹងពូអត់មានរៀនចំការអីបានទេ?

ហមៈ អត់ទេ កាលហ្នឹងអត់មានទេហើយដីស្រែក៏អត់មានបានចាប់អីគេដែរ ដល់នៅៗពូថាគេចាប់ស្រែក៏ទៅចាប់ស្រែឈូសស្រែហ្នឹងជិតបាន៩រ៉ៃហ្នឹង ខ្ញុំឈូសយកបណ្តោយអស់៤០០០ ។

ប៊ុនថនៈ អស់៤០០០បាត?

ហមៈ បាទ!ជួលអាសនីគេឈូស ។

ប៊ុនថនៈ ចឹងឈូសអត់មានខ្លាចគ្រាប់មីនទេ?

ហមៈ អត់ទេ ឈូសអាលើមីនហ្នឹងហើយអាមីនក្តាហ្នឹង ។

ប៊ុនថនៈ ឈូសចេញតែម្តង?

ហមៈ បាទ!ឈូសចេញតែម្តង ឲ្យថៃភ្ជួរឲ្យ គាយុនភ្ជួរឲ្យ ។

ប៊ុនថនៈ ចឹងបើសិនជាផ្ទុះអីមានគ្រោះថ្នាក់ទេពូ?

ហមៈ មានគ្រោះថ្នាក់ដែលហ្នឹងតែគាត់មិនខ្លាចផង តា សាននៅផ្ទះត្រង់នេះឈូសដែរ ។

ប៊ុនថនៈ ចឹងអត់ដែលមានគ្រោះថ្នាក់អីទេ?

ហមៈ	អត់គ្រោះថ្នាក់ គ្នាខ្ញុំម្នាក់ឈូសហើយវាមក ថ្ងៃនោះវាបើខ្ញុំវាមីនឲ្យបងឯងសុំស្រូវមួយតៅ ខ្ញុំសួរថាអាពេញឯងស្គាល់លិចកើតអត់ វាថាអត់ ខ្ញុំថាឯងថ្ងៃនេះច្បាស់ជាផុះមីនហើយ ។

ប៊ុនថនៈ	បាទ ។

ហមៈ	ផុះមីនមែន បិតមុខបែកភ្នែកអស់មួយចំហៀង ឃើញមីនវាអន្តុយបុកលេង ឥឡូវវានៅល្វា ។

ប៊ុនថនៈ	ចឹងកាលពូមកបានចាប់ផ្ទះនៅហ្នឹងហើយបានមកនៅនេះក្រោយពូ?

ហមៈ	អានេះនៅក្រោយទេ ។

ប៊ុនថនៈ	បាទ ។

ហមៈ	ស្គាល់វាទៅវិញគេ មកនៅនេះវិញគេអស់៥៥០០ ។

ប៊ុនថនៈ	៥៥០០បាត?

ហមៈ	បាទ ។

ប៊ុនថនៈ	ចឹងកាលហ្នឹងគេនៅបើរបបឲ្យដែរ?

ហមៈ	បើរបបឲ្យនិយាយរបបគេបើកឲ្យរាល់ថ្ងៃឲ្យលុយ មួយខែបើកៗ ។

ប៊ុនថនៈ	ចឹងពូនៅកងទ័ពដដែល?

ហមៈ	នៅដដែល នៅតែក្រោយគេ គេអត់ប្រើទេណាស់ ខ្ញុំតាំងពីដាច់ខ្លួនមកគេអត់ប្រើផង ។

ប៊ុនថនៈ	ចឹងដល់ពេលត្រូវការអីគេហៅទៅប្រជុំទៅបន្ទាយអីទេ?

ហមៈ	អត់ទេ គេឈប់ហៅហើយឲ្យខ្ញុំមកខាងសោធនគេកាត់មកឲ្យនៅក្រោយវិញ បើតែលុយយកទេឥឡូវ ។

ប៊ុនថនៈ	មួយខែបានប៉ុន្មានដែរ?

ហមៈ	មួយបាន២៥០០-២៦០០ ។

ប៊ុនថនៈ	បានច្រើនដែរ ចឹងជាងពីរសែន ។

ហមៈ	លុយខ្មែរយើងណាស់ លុយខ្មែរយើង២៦ម៉ឺន ។

ប៊ុនថនៈ	ចឹងរបបអីគេអត់បើទេ?

ហមៈ	អត់ទេ ខោអាវអស់ហើយអង្ករអីគេឲ្យតែលុយ នៅតែលុយគោលនយោបាយមិនទាន់បានបើក ។

ប៊ុនថនៈ	ចឹងគេមានហៅពូទៅប្រជុំអីទេ?

ហមៈ	អត់ទេ គេអត់ដែលហៅទេ មានតែគណបក្សអីគេហៅទៅប្រជុំអី ។

ប៊ុនថន៖ បាទ ។

ហម៖ យើងចូលគណបក្សនេះគណបក្សនោះ ។

ប៊ុនថន៖ ចឹងពូមិនដែលមានគ្រោះថ្នាក់អីទេ?

ហម៖ អត់ទេ ។

ប៊ុនថន៖ ចឹងដូចជាអ្នកពិការអីមានគេនៅបើកឲ្យដែលពូ?

ហម៖ បើកដូចគ្នាអ្នកពិការ តាហ្នឹងក៏ពិការដែរ អ្នកពិការគេបានច្រើនជាងខ្ញុំ ។

ប៊ុនថន៖ បាទ ។

ហម៖ ខ្ញុំគិតទៅបាន៦លានហើយ អេ!៥លាន ៦ហើយតាំងពីបើកមកនេះប៉ុន្មានខែហ្នឹង ។

ប៊ុនថន៖ ៦លាន?

ហម៖ ៦លានលុយខ្មែរហ្នឹង ។

ប៊ុនថន៖ ចឹងអ្នកពិការគេមានដីសម្បទានឲ្យដែលពូ?

ហម៖ ទេ ទើបប៉ុន្មានថ្ងៃហ្នឹងគេឲ្យអ្នកអត់ ឃើញអ្នកអត់ៗគេតាសឿនហិរញ្ញវត្ថុគេហៅទៅធ្វើការ ។

ប៊ុនថន៖ បាទ ។

ហម៖ មេភូមិហ្នឹងគេដើរកត់ឈ្មោះ ។

ប៊ុនថន៖ ចឹងអ្នកអត់គេជួយខត្តមឲ្យ?

ហម៖ គេជួយខត្តមមិនថាគេឲ្យកន្លែងណាទេណាស់ អ្នកអត់ដូចខ្ញុំចេះគេមិនឲ្យផង ខ្ញុំមិនថាអីទេ ខ្ញុំថាឲ្យអ្នកអត់ចុះ ខ្ញុំប្រាប់មេភូមិដែលហ្នឹង បងឯងចែកអ្នកអត់សិនទៅ អ្នកមានដីលក់អស់ហើយចែកទៀតម៉េចកើត អាគ្នាអ្នកសោះ ។

ប៊ុនថន៖ បាទ ។

ហម៖ ខ្ញុំប្រាប់គាត់ដែលហ្នឹង ។

ប៊ុនថន៖ ចឹងអ្នកខ្លះមានដីតែលក់?

ហម៖ លក់ អ្នកនៅត្រង់នោះមានដីតែ តែលក់អស់ សុំគេទៀត ។

ប៊ុនថន៖ ចឹងមានអ្នកដែលអត់ពីមុនមកទេ?

ហម៖ មានអ្នកអត់ពូមុនមកដូចអឺ តក់អីគាត់អត់ គាត់ទៅថៃហើយ គាត់លក់ផ្ទះគាត់អស់ហើយ ហ្នឹងគាត់ជាអ្នកអត់មែនទែន ។

ប៊ុនថន៖ ចឹងខ្ញុំចង់សួរពូដឹបបួងសមាហរណ៍កម្មមុន៩៦-៩៧ពូ?

ហម៖ ទេ សមាហរណ៍កម្មហ្នឹងមិនដឹងជា៩០ប៉ុន្មាន មិនដឹងជា៩៧អីហ្នឹង ។

ប៊ុនថន: ដូចជាជីវភាពពូដូចជាការរស់នៅខុសប្លែកគ្នាទេ?

ហម: ខុសប្លែកមែនទែន តាំងពីនោះមកដល់ឥឡូវហ្នឹងវាសប្បាយជាងមុន និយាយរឿងរកស៊ីវាស្រួល និយាយស្រួលវាដដែលៗស្រែក៏ធ្វើបានអត់តែឆ្នាំនេះខ្ញុំមិនបានធ្វើ។

ប៊ុនថន: ចឹងរាល់ឆ្នាំពីធ្វើ?

ហម: ខ្ញុំធ្វើតែចំការ រាល់ឆ្នាំធ្វើតើ ឆ្នាំនេះមានអីអត់ អត់មានភ្លៀងចេះអត់បានធ្វើ ហើយចំការដាំដំឡូងទាំងអស់។

ប៊ុនថន: ចឹងបានផលទេ រាល់ឆ្នាំ?

ហម: ទេ ចំការទើបដាំដំឡូងមួយឆ្នាំ ខ្ញុំធ្វើមិនដែលខាតទេធ្វើ។

ប៊ុនថន: ចឹងគ្រឿងចក្រអីខ្លួនឯង?

ហម: អត់ទេ ជួលគេ ឆ្នាំនេះអស់២៣០០០ ភ្ជួរណាស់ លើករងលើកអីអស់២៣០០០ គ្រាន់តែចំការនៅដាំស្រែនេះមិនគិត។

ប៊ុនថន: ចឹងពូអត់មានគ្រឿងចក្រធ្វើខ្លួនឯងទេ អត់មានអាត្រាក់អី?

ហម: អត់មានអាត្រាក់ទេ មានគោយន់ អាត្រាក់ជួលគេភ្ជួរ។

ប៊ុនថន: និយាយពូតាំងពីបែកផ្ទះហ្នឹងពូមានដែលទៅលេងទេ?

ហម: ទៅ ទៅស្រុក។

ប៊ុនថន: ទៅបានច្រើនដងទេ ទៅស្រុកហ្នឹង?

ហម: ទេ មិនដឹងជាប៉ុន្មានដងទេ មិនបានរាប់ផង។

ប៊ុនថន: ចឹងខស្សាហ៍ទៅទេពូ?

ហម: អត់ខស្សាហ៍ទេ និយាយរឿងទៅនោះ មិនសូវបានទៅប៉ុន្មានទេ ទៅបានប៉ុន្មានដងហ្នឹង។

ប៊ុនថន: ទៅក្រោយសមាហរណ៍កម្មហើយពូទៅ?

ហម: បាទ! កាលសមាហរណ៍កម្មហើយបានទៅមួយសារ ទៅជួបម៉ែឪ ទៅម៉ែឪងាប់អស់កាលហ្នឹងផ្តាច់ខ្លួនហើយទៅ ទៅឆ្ងាយដល់អន្តរ។

ប៊ុនថន: ទៅដល់ណាវិញ?

ហម: ទៅដល់អន្តរធំនោះ។

ប៊ុនថន: ទៅសៀមរាប?

ហម: ទៅពីរនាក់និរសាខ្ញុំបុកទៅតែម្តង ម៉ូតូមួយសើច...។

ប៊ុនថន: សមាហរណ៍កម្មហើយហ្នឹង?

ហម: បាទ។

ប៊ុនថន៖ ពូមាននិរសាដែរ?

ហម៖ មានខ្ញុំសក្តិ២ ។

ប៊ុនថន៖ ពូសក្តិ២កាន់កូនទាហានប៉ុន្មាននាក់ដែរ?

ហម៖ ៣០នាក់ កងតូចខ្មែរក្រហម ។

ប៊ុនថន៖ បាទ ។

ហម៖ និរសាខ្ញុំគេខឹងផងធ្លាប់បងប្អូនគេនៅសៀមរាបនោះ ជា ចាន់ថាហ្នឹងបុកទៅអន្តរម៉ូតូអន្តព្រីយ៉ានោះសើច... ។

ប៊ុនថន៖ ទៅរកបងប្អូន?

ហម៖ ទៅរកបងប្អូនគេនោះ ។

ប៊ុនថន៖ ទៅបានជួបទេ?

ហម៖ ជួបទៅដល់គេកំពង់តែប្រជុំកន្លែងអន្តរធំនោះ គេកាក់គេយាមជាប់ ដល់ជា ចាន់ថាចេញមកបានគេឲ្យចូល ហើយនិរសាខ្ញុំអាហ្នឹងសង្ហាណាស់ ឥឡូវវានៅខាងព្រៃយើងនេះ សួររកពីរកអាអូនៗ ឃើញហើយ ។

ប៊ុនថន៖ ឥឡូវគាត់ធ្វើការអី?

ហម៖ ធ្វើទាហានរាល់ថ្ងៃ ទាបកាតិចតែដល់ហើយ វានៅបុំារអាហ្នឹង កាងដល់ហើយវានៅខាងព្រៃ ។

ប៊ុនថន៖ ខាងបរិស្ថាន?

ហម៖ បាទ! បើមិនជឿទៅសួរទៅ ឲ្យតែទៅជាមួយកាំភ្លើងខ្លីវាចេះ តូចទេ ។

ប៊ុនថន៖ បាទ ។

ហម៖ ការធ្វើសង្គ្រាមជាមួយខ្ញុំដល់ហើយ វវល់តែថាខ្ញុំ ខ្ញុំវាអត់ហ៊ុំហារនោះ ។

ប៊ុនថន៖ ចឹងពូអត់មានកាំភ្លើងខ្លីទេ?

ហម៖ មាន ។

ប៊ុនថន៖ តែពូបញ្ចេញអី?

ហម៖ បាទ! ខ្ញុំអត់សង្ហាដូចវា មេគេចូលចិត្តយកវាណាស់ មេអ្នកធំអីទៅណាយកវាទៅ រាងវាកាងណាស់ ។

ប៊ុនថន៖ ចឹងពូទៅពីរគាត់ហ្នឹងទៅផ្ទះពូដែរ?

ហម៖ ទៅផ្ទះខ្ញុំដែរ ទៅដេកមួយយប់ទិញគោអីឲ្យបងប្អូនស៊ី ។

ប៊ុនថន៖ កាលហ្នឹងនៅមានលុយដែរ?

ហមៈ មាន មានលុយទិញគោហើយបានទៅអន្ការ ។

ប៊ុនថនៈ ចឹងកាលផ្តាច់ខ្លួនហើយពូពាក់ឯកសណ្ឋានទៅ?

ហមៈ បាទ ។

ប៊ុនថនៈ ឯកសណ្ឋានខាងខេមភូមិន្ទ?

ហមៈ ឯកសណ្ឋានទាហាន ខាងខេមភូមិន្ទស៊ុំច្បាប់គេ ។

ប៊ុនថនៈ ចឹងកាលហ្នឹងពូនៅកាន់កូនទាហានដដែល?

ហមៈ កាន់ ដល់គេដកចំរុះគ្នាខាងក្នុងខ្មែរក្រហមទៅបានគេធិបខ្ញុំទុក ។

ប៊ុនថនៈ ពូអស់កូនទាហានហើយ?

ហមៈ អស់ ។

ប៊ុនថនៈ ចឹងកាលពូទៅដល់ដំបូងហ្នឹងឪពុកម្តាយស្លាប់ហើយ?

ហមៈ ស្លាប់ផុតបាត់ ។

ប៊ុនថនៈ ចុះប្អូននិងបង?

ហមៈ បងខ្ញុំនៅទាំងពីរហ្នឹងប្អូនខ្ញុំនិងខ្ញុំនៅ មួយនៅល្វារកានេះ ។

ប៊ុនថនៈ បាទ ។

ហមៈ ហើយបងខ្ញុំពីរទៀតនៅស្រុកនោះ រស់ទាំងអស់បងប្អូនខ្ញុំ តែបងខ្ញុំចាស់ៗអស់ ។

ប៊ុនថនៈ ចឹងតាំងពីឆ្នាំ៧៩ហ្នឹងពូបែកផ្ទះរហូត?

ហមៈ បាទ!បែករហូត ។

ប៊ុនថនៈ មានដែលទទួលដំណឹងពីគាត់ទេ?

ហមៈ អត់ទេ ។

ប៊ុនថនៈ ចឹងពូបានចំណាំភូមិចំណាំអីដែរ?

ហមៈ ចំណាំបានតើ ដល់ខ្ញុំទៅធ្វើការនៅក្នុងចឹងទៅជួបអ្នកស្រុកចេះតែសួរគេទៅដឹងថាបងប្អូននៅពីដើមខ្ញុំឲ្យគេទៅយកបានប្អូនខ្ញុំមកបាញ់គ្នាជាប់ចៅកែយ៉ហ្នឹង ខ្ញុំទៅស្មាក់យកមកហ្នឹងជួលគេទៅយកណាស់ ។

ប៊ុនថនៈ ចឹងជួលគេទៅយកពីស្រុកមក?

ហមៈ បាទ!ជួលគេទៅយកពីស្រុកមកឈ្មោះបងម៉ៅៗគាត់ទៅយក ។

ប៊ុនថនៈ កាលហ្នឹងមិនទាន់លសមាហរណ៍កម្មទេ?

ហមៈ អត់ទេ កំពង់តែបាញ់គ្នា ឲ្យទៅយកបងគាត់ទៅយកប្អូនខ្ញុំមក យកអាហានមក ។

ប៊ុនថនៈ ចឹងយកមកគាត់មកនៅហ្នឹង?

ហមៈ មកដល់នេះបងម៉ែនគាត់នៅខាងស្មៀនគាត់នៅ៩៣ហ្នឹង សរសេរឈ្មោះហើយប្រាប់ខ្ញុំឲ្យទៅយក ខ្ញុំទៅជាមួយគា ប៉ុនកាលហ្នឹង ។

ប៊ុនថនៈ យកមកនៅហ្នឹងរាល់ថ្ងៃ?

ហមៈ អត់ទេ យកមកលេងតែប៉ុន្មានថ្ងៃហ្នឹងខ្ញុំឲ្យទៅវិញ ទៅក៏រហេមរហាមទាហានខ្មែរចាប់ផងដល់ស្រុកបាត់បាត់ហើយ ឥឡូវមានប្រពន្ធហើយ ។

ប៊ុនថនៈ ចឹងនៅរស់ទាំងអស់?

ហមៈ នៅរស់ទាំងអស់ ។

ប៊ុនថនៈ ចឹងស្លាប់តែឪពុកម្ដាយទេ?

ហមៈ បាទ ។

ប៊ុនថនៈ ចឹងដល់ពេលក្រោយសមាហរណ៍កម្មហ្នឹងបានពូទៅម្ដងទៀត?

ហមៈ ទៅមួយម្ដងទៀត ។

ប៊ុនថនៈ ចឹងពេលទៅជួបបងប្អូនស្គាល់ទេ?

ហមៈ ស្គាល់ទាំងអស់ អត់តែក្មេងៗដែលមិនដែលស្គាល់វា ។

ប៊ុនថនៈ ចឹងកាលពូទៅដំបូងមានអារម្មណ៍យ៉ាងម៉េចទៅ បែកស្រុកយូរអីចឹង?

ហមៈ និយាយទៅយំ យំឃើញបងប្អូនក្រយំ ។

ប៊ុនថនៈ ចឹងបងប្អូនអីមានអារម្មណ៍ជាមួយពូដែលបែកយូរ?

ហមៈ យំ ពិសេសខ្ញុំបងខ្ញុំមិនសូវអីទេ ខ្ញុំឃើញផ្ទះអីនឹកឃើញម៉ែខ្ញុំ

ប៊ុនថនៈ ចឹងកាលពូបែកចេញកាលឆ្នាំ៧៥ហ្នឹងពូមាននឹកផ្ទះដែរ?

ហមៈ អត់ទេ មិនសូវនឹកផងខ្ញុំនៅក្មេងខ្ញុំគិតតែពីសប្បាយមិនសូវគិតអីទេ សប្បាយគេចាប់គេគេចង់អីអត់មានព្រួយបារម្ភណ៍អីទេ គិតតែពីសប្បាយតែម្ដង សប្បាយឡើងមែនទែនទៅណាស់ ។

ប៊ុនថនៈ បាទ ។

ហមៈ ដូចខ្ញុំនិយាយដដែលៗ នៅទូតចិនព្រឹកឡើងនំសណ្ដែកដីស្ងោទាំងឆ្នាំងៗ នំស៊ីជីកឡើងសប្បាយ ។

ប៊ុនថនៈ នៅហ្នឹងមានដើរលេងអីទេ?

ហមៈ ដើលេងគ្មានពីណាហ៊ានកាក់ទេ ។

ប៊ុនថនៈ ចឹងបានដើរលេងលែងដែរ?

ហមៈ ដើរលេងពេញតែភ្នំពេញហ្នឹង ចង់ដើរគ្មានពីណាហ៊ានកាក់ទេ ។

ប៊ុនថន៖ ចឹងយ៉ាងម៉េចបានជាគេមិនហ៊ានសួរ?

ហម៖ គេដឹងថាយើងនៅជាមួយភ្ញៀវនោះ ។

ប៊ុនថន៖ បាទ ។

ហម៖ គេស្គាល់នោះ ។

ប៊ុនថន៖ ចឹងមានកាតមានអីបង្ហាញទេ?

ហម៖ អត់ទេ ចុះគេស្គាល់គេចេញចូលទាហានអី គេយាមនោះ គេនៅហ្នឹងគេយាមគេស្គាល់មុខហ្នឹង ។

ប៊ុនថន៖ ចឹងមានដើរទៅវ៉ាំងអីទេ?

ហម៖ ដើរជិះឡានជាមួយភ្ញៀវជាមួយអី ជិះទៅណាឲ្យតាពាស ទៅយកដំរីកៅស៊ូអីពេញហ្នឹងគ្មានពីណាហៅកាក់ទេ ។

ប៊ុនថន៖ ទៅយកដំរីកៅស៊ូនៅកំពង់ចាបហ្នឹងពូ?

ហម៖ ទេ នៅភ្នំពេញហ្នឹង កន្លែងមាត់ទន្លេហ្នឹង បើចិនត្រូវការទៅ ទៅយកទៅជិះឡានជាមួយភ្ញៀវមានពីណាថាទេ ។

ប៊ុនថន៖ បានទៅកន្លែងណាខ្លះពូ?

ហម៖ នៅជុំវិញភ្នំពេញរាប់មិនអស់ទេ ដើរគគីក ។

ប៊ុនថន៖ ចឹងមានដើរទៅផ្សារថ្មីអីទេ?

ហម៖ ផ្សារថ្មីហ្នឹងមានតិចសារណាស់ទេ សើច... ។

ប៊ុនថន៖ ចឹងនៅផ្សារថ្មីហ្នឹងមានលក់ឥវ៉ាន់អីទេ?

ហម៖ មានលក់ត្រីអីពេញតែហ្នឹង ។

ប៊ុនថន៖ មានលក់ត្រីដែរ?

ហម៖ បាទ ។

ប៊ុនថន៖ ចឹងមានគេចាយលុយអីដែរ យើងទិញចឹង?

ហម៖ មិនជាចាយស្អីគេ បើមិនដែលមានលុយជងកាលហ្នឹង ។

ប៊ុនថន៖ ចឹងពូចូលទៅលេង?

ហម៖ ទៅជាមួយភ្ញៀវ ឃើញគេទិញស្អីគេណាស់ មិនដឹងជាលុយអី ។

ប៊ុនថន៖ មានលក់ច្រើនគ្នាទេ?

ហម៖ លក់ច្រើនតើ បើយើងនៅតែលើឡានមិនដឹងសួរគេ ថាលុយអីៗ យើងអត់មានលុយនោះ ។

ប៊ុនថន៖ បាទ ។

ហម៖ យើងនៅចាំតែស៊ីនៅកន្លែងទូតចិនមានលំបាកអី មានចុងភៅគេដាំឲ្យស៊ីតើ ។

ប៊ុនថន៖ ទៅជាមួយភ្ញៀវចិនហ្នឹងទៅច្រើនទេ?

ហម៖ ទៅច្រើន គេត្រូវការ១០នាក់ទៅ ទៅលើកកៅស៊ូអីណា គេត្រូវការយកអីទៅគេប្រើយើងទៅណាស់ ទៅកើបគ្រួសអីក៏ទៅៗ ។

ប៊ុនថន៖ បាទ ។

ហម៖ បើគេត្រូវការ១០នាក់ គេយក១០នាក់ទៅ គេត្រូវការ២០នាក់យក២០នាក់ទៅ កើបគ្រួសជាមួយស្រីៗនៅមាត់ទន្លេហ្នឹង ទៅមួយយប់អីក៏មកវិញទៅសើច... មិនសូវគិតអីទេ ពេលឈឺគេយកទៅកន្លែងតា ព្រំ ។

ប៊ុនថន៖ តា ព្រំហ្នឹងកន្លែងណា?

ហម៖ កន្លែង«ក៤» ។

ប៊ុនថន៖ កន្លែង«ក៤»?

ហម៖ បាទ!កន្លែងពេទ្យហ្នឹង មន្ទីរ ។

ប៊ុនថន៖ យ៉ាងម៉េចបានជាគេហៅតា ព្រំហ្នឹង?

ហម៖ ចុះគេឈ្មោះ តា ព្រំហ្នឹង ។

ប៊ុនថន៖ ចឹងតា ព្រំហ្នឹងគាត់ជាប្រធានពេទ្យ?

ហម៖ ប្រធានមន្ទីរ«ក៤» ។

ប៊ុនថន៖ ចឹងប្រធានមន្ទីរ«ក៤»?

ហម៖ បាទ! ក្រសួង៨៧០ ។

ប៊ុនថន៖ បាទ ។

ហម៖ ឲ្យតែយើងឈឺនៅទូតចិនហ្នឹងគេយកទៅដាក់នៅហ្នឹងហើយ ។

ប៊ុនថន៖ ចឹងមេក្រសួងតែម្ដងគាត់ឈ្មោះអីវិញ?

ហម៖ មិនស្គាល់ទេ មិនដឹងជាពីរណាគ្រប់គ្រងក្រសួង៨៧០មិនដឹងជាពីរណា យើងមិនស្គាល់គេអស់ទេ ។

ប៊ុនថន៖ តែពូនៅជាប់ជាមួយចិនៗ?

ហម៖ បាទ!នៅជាមួយចិនជាកម្មករ ។

ប៊ុនថន៖ ចឹងកាលពូទៅផ្សារថ្មីហ្នឹងពូអត់មានបានចូលទៅផ្សារថ្មីទេ?

ហម៖ អត់មានបានចុះទេ អង្គុយនៅលើឡានមើលគេទិញនេះ ទិញនោះ ។

ប៊ុនថន៖ ចឹងមានចុះតែចិនៗទេ?

ហម៖ ចិនមានខ្លះគេទៅទិញឥវ៉ាន់ទៅ យើងមានអីយើងជាកម្មករអន្តុយមើលគេទៅមិនដឹងជាគេចាយលុយស្អីៗ ត្រឹម១៩ហ្នឹងក៏មិនដែលមើលគេ ។

ប៊ុនថន៖ ឡានអីវិញដែលពួជិះ?

ហម៖ ឡានចិន ។

ប៊ុនថន៖ ឡានធំឬឡានតូច?

ហម៖ ឡានទូអាសៗហ្នឹង ។

ប៊ុនថន៖ ចឹងតូចៗពូ?

ហម៖ បាទ!តូចទេ ជិះពេញតែក្នុំពេញហ្នឹង គេត្រូវការទៅណាទៅ ។

ប៊ុនថន៖ ចឹងផ្សារថ្មីហ្នឹងលក់ចុំវិញផ្សារតែម្តង?

ហម៖ ទេ មិនបានដើរជុំទេ ឃើញតែអែបថ្នល់ចេះ ឃើញគេលក់ចឹងទៅណាស់ហ្នឹងហើយយើងមិនបានចុះដើរមើលទេ គ្រាន់តែបានជិះឡានដើរលេង ។

ប៊ុនថន៖ ចឹងលក់តែត្រីទេ អត់មានឃើញលក់បន្លែ លក់ខោអាវទេ?

ហម៖ មិនដឹងជាគេលក់ស្អីខ្លះ ខោអាវអីយើងមិនបានពិនិត្យផង ។

ប៊ុនថន៖ ចឹងផ្ទះជុំវិញផ្សារថ្មីហ្នឹងមានមនុស្សនៅទេ?

ហម៖ មាននៅតើ កាលនោះនៅ ។

ប៊ុនថន៖ មានមនុស្សនៅ?

ហម៖ ៧៧-៧៨ហ្នឹងមានមនុស្សឡើងណែនប៉េះហ្នឹង យី!សល់ដែលបូរីកីឡាអីអត់មាននុស្សនៅទេ តិចណាស់ ថាក្រៅពីនោះផ្ទះនៅផ្សារថ្មីអីមានមនុស្សច្រើន ៧៧-៧៨ហ្នឹង ។

ប៊ុនថន៖ បាទ ។

ហម៖ ហ្នឹងហើយមនុស្សឡូប៉ប្រិះ ។

ប៊ុនថន៖ ចឹងនៅផ្សារថ្មីហ្នឹងភាគច្រើនប្រជាជនឬមួយអ្នកធ្វើការពូ?

ហម៖ ទេ ខ្ញុំមិនសូវដឹងទេ កាលហ្នឹងអត់មានបានសួរគេទេ ។

ប៊ុនថន៖ តែឃើញមនុស្សដើរ?

ហម៖ ឃើញគេដើរ ឃើញគេលក់ឥវ៉ាន់ យើងគ្រាន់តែជិះឡានដើរ ។

ប៊ុនថន៖ ចុះប្លែកពីឥឡូវទេ?

ហម៖ ទេ ខ្ញុំមិនដែលទៅផង ខានទៅយូរហើយ ។

ប៊ុនថន៖ បើទៅឥឡូវបានឃើញប្លែក?

ហមៈ		និយាយថាលក់ដំឡូងហើយខ្ញុំនាំកូនទៅលេងខាងប្រពន្ធ ។

ប៊ុនថនៈ		គាត់នៅណា?

ហមៈ		ប្រពន្ធខ្ញុំនៅភ្នំពេញ បងប្អូនប្រពន្ធខ្ញុំខ្លះនៅភ្នំពេញខ្លះនៅកំពង់សោម ។

ប៊ុនថនៈ		ចឹងមានដែលបានចូលវាំងលេងទេ?

ហមៈ		អត់ទេ មើចហ៊ានចូល ។

ប៊ុនថនៈ		ចឹងអត់មានដែលបានចូលជាមួយភ្ញៀវចិនទេ?

ហមៈ		អត់ទេ គេមានដែលឲ្យចូល ។

ប៊ុនថនៈ		ចឹងក្រៅពីផ្សារថ្មីពូមានបានដើរទៅកន្លែងណាខ្លះទៀត?

ហមៈ		ទេ មិនបានរាប់ទេ គ្រាន់តែបានដើរជាមួយភ្ញៀវចឹងទៅណាស់ ។

ប៊ុនថនៈ		បាទ ។

ហមៈ		ហ្នឹងហើយជិះឡានទៅកន្លែងគេកើបថ្ម ជញ្ជូនកៅស៊ូ ដ័រកៅស៊ូពីមាត់ទន្លេ ។

ប៊ុនថនៈ		កន្លែងដែ?

ហមៈ		កន្លែងដែ កន្លែងគេជញ្ជូនពីមាត់ទន្លេមក ។

ប៊ុនថនៈ		គេយកទៅណាកៅស៊ូហ្នឹង?

ហមៈ		ទេ មិនដឹងជាគេយកទៅណា ។

ប៊ុនថនៈ		ទៅដឹកមក?

ហមៈ		យើងគ្រាន់ទៅយកមកឲ្យចិនហ្នឹង ។

ប៊ុនថនៈ		បាទ ។

ហមៈ		គេត្រូវការហៅយើងទៅលើកទៅ កម្មករគេ គេប្រើចេះតែទៅហើយ ។

ប៊ុនថនៈ		តែសប្បាយ?

ហមៈ		សប្បាយ ចុះយើងនៅក្មេងមានលំបាកអី ធាត់ខោស្លៀកឡើងណែនប៉េះ ។

ប៊ុនថនៈ		ចឹងប្លែកទេ តាមផ្លូវមានមនុស្សប្រមូលស្ងាត់មនុស្ស?

ហមៈ		ពូមុនស្ងាត់ ដូចនៅភ្នំពេញហ្នឹងអត់មានមនុស្សនៅពេញទេ តាមផ្ទះហ្នឹងណាស់ បូរីកីឡាអី អត់សូវមានមនុស្សទេ ខ្ញុំឡើងលាងពេញតែហ្នឹងគេប្រើ ។

ប៊ុនថនៈ		ទៅលាងនៅហ្នឹង?

ហមៈ		បាទ!លាងហើយដាំបាយអន្តរអាមេរិកាំងស៊ី ។

ប៊ុនថនៈ		ដាំខ្លួនឯង?

ហមៈ ដាំខ្លួនឯងអាអង្ករទន់ៗ គេនោះ ចាក់តែប្រេងទៅដាក់នេះទៅឆ្អិនបាត់ កំសៀវអីចេះតែដាំស៊ីទៅ ។

ប៊ុនថនៈ មានម្ហូបអីគ្រប់ទេ?

ហមៈ មាននៅលើផ្ទះថ្មហ្នឹង ខ្ញុំឆក់ខ្សែភ្លើងម្ដងនិយាយកុហក ខ្ញុំមុជទឹកទៅក្បែរផ្ទះហ្នឹងឆក់ឡើងទាញឡើង ចឹងបានជាឈឺចង្កេះហ្នឹង ។

ប៊ុនថនៈ អត់អីដែរ?

ហមៈ អត់ អត់ដឹងថាខ្សែភ្លើងវាដាច់ណា តាមទ្វារតាមអីទៅចាប់នោះ សើមអត់បានទេ ។

ប៊ុនថនៈ ឆក់ពូតែអត់មានគ្រោះថ្នាក់ដែរ?

ហមៈ អត់ ដល់យូរៗបានដឹង ។

ប៊ុនថនៈ ចឹងមានមនុស្សមានតែនៅម្តុំផ្សារទេ កន្លែងផ្សេងទៀតមានទេ?

ហមៈ កន្លែងខ្លះមានខ្លះដែលតែវាមិនមាននៅពេញផ្ទះទេ ខ្ញុំទៅហើយបូរីកីឡាខ្ញុំទៅលាងទឹកកាត់ស្មៅអីពេញតែហ្នឹង ។

ប៊ុនថនៈ ចឹងបូរីកីឡាក៏អត់មានមនុស្សដែរ?

ហមៈ អត់ទេ រទេះដួរវែងតាមថ្នល់សុទ្ធតែខ្ញុំលាង ។

ប៊ុនថនៈ ចឹងមានដែលទៅលេងតាមខេត្តអីទេពូ?

ហមៈ អត់ទេ នៅតែភ្នំពេញហ្នឹងឯង យើងធ្វើការចេះមានគេឲ្យដើរទៅឆ្ងាយ មួយអាទិត្យអីគេឲ្យសម្រាកទៅយើងដើរលេងទៅ បើកន្លែងណាគេមានបញ្ចាំងកុនទៅ គេមកយកទៅ គេយកឡានមកយកទៅមើលទៅ ខោអាវគេកាត់ស្អែកឡើងគេវាស់ឲ្យ ។

ប៊ុនថនៈ បាទ ។

ហមៈ សប្បាយណាស់ កាលនៅក្មេងកាលហ្នឹង ។

ប៊ុនថនៈ ចឹងកុនពូបានទៅមើលដែរ គេឌុបទៅមើលដែរ?

ហមៈ ទៅមើល ។

ប៊ុនថនៈ ទៅមើលនៅណាពូ?

ហមៈ ទៅខាងលិចពោធិចិនតុងដឹងផ្សារស្អីគេ ។

ប៊ុនថនៈ ផ្សារពោធិចិនតុងឬផ្សារអីវិញ?

ហមៈ ទេ ផ្សារស្អី... ។

ប៊ុនថនៈ នៅក្នុងភ្នំពេញ?

ហមៈ នៅក្នុងភ្នំពេញហ្នឹងឯង ។

ប៊ុនថន៖ ផ្សារដើមគរ?

ហម៖ ផ្សារហ្នឹងហើយ ផ្សារហ្នឹងឯង ទៅអង្គុយតុហ្នឹងដាក់ទៅស៊ីតៗនាំគ្នាសប្បាយសើច...ហ៊ោពេញហ្នឹង ។

ប៊ុនថន៖ ពូអត់ដែលបានទៅ?

ហម៖ អត់ដែលបានទៅ ប្រុសៗសប្បាយវាអរសើច... ។

ប៊ុនថន៖ ប្លែកទេពូ?

ហម៖ ឥឡូវមិនដែលបានទៅទេ ពីមុនមិញវាប្លែកដែរ វាប្លែកមិនដូចលើកមុន មិនដូចឥឡូវ ។

ប៊ុនថន៖ កាលទៅមើលមានមនុស្សច្រើនទេពូ?

ហម៖ មានមនុស្សតិចទេ ឡើងពេញ ។

ប៊ុនថន៖ មើលរឿងអីពូមាននៅចាំទេ?

ហម៖ មិនដឹងជារឿងស្អីទេ មិនចាំទេ ថាដូចខ្ញុំនិយាយប្រាប់ចឹងគិតតែពីសប្បាយហ្នឹងមិនសូវបានមើលប៉ុន្មានទេ មើលស្រីៗវាច្រើននោះ ។

ប៊ុនថន៖ ចឹងទៅលេងសើចអីបានដែរពូ?

ហម៖ ចុះមានស្អីមានពីណាគេថាអី ស្រីៗឡើងបីបួនឡានទៅ ទៅជាមួយគ្នាហ្នឹង ។

ប៊ុនថន៖ ស្រីៗមកពីកងផ្សេងឬមួយយ៉ាងម៉េច?

ហម៖ ស្រីៗនៅ៨៧០ហ្នឹង នៅជាមួយគ្នាហ្នឹងគេទៅ ។

ប៊ុនថន៖ តែមានមកពីខាងក្រសួងផ្សេងទេ?

ហម៖ ក្រសួងផ្សេងក៏មាន ។

ប៊ុនថន៖ លាយគ្នាទៅ?

ហម៖ បាទ!លាយគ្នាទៅ ក្រុមគេក៏ទៅក្រុមយើងក៏ទៅជុំគ្នាទៅ អាស៊ីមដឹកទៅគគ្រឹកគគ្រេងទៅដល់នោះគេដាក់ទៅលោតជិះរៀងខ្លួនទៅ ។

ប៊ុនថន៖ រឿងកុនអត់មានដូចឥឡូវរឿងស្នេហាអីទេ?

ហម៖ ទេ មិនដឹងជារឿងស្អីទេ មិនបានចាប់អារមណ៍ដែលខ្ញុំ មិនសូវគិតគូទេរឿងចឹង ។

ប៊ុនថន៖ ចឹងគ្រាន់តែទៅលេងសប្បាយ?

ហម៖ បាទ!គ្រាន់តែទៅឲ្យសប្បាយហ្នឹង ចឹងមានពិបាកអីសប្បាយហួសហេតុ សប្បាយឡើងតា ម៉ុលគាត់ធ្វើបាបហ្នឹងហើយ គេថាយើងគេណែនាំអត់បាន ។

ប៊ុនថន៖ ចឹងផ្សារដើមគរមានមនុស្សនៅទេ?

ហម៖ មានតើ ។

ប៊ុនថន: មានលក់ឥវ៉ាន់ទេ?

ហម: ទេ លក់ឥវ៉ាន់មិនដែលឃើញលក់ទេ ឃើញតែមនុស្សទៅគ្រប់គ្រងហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

ហម: កាលនៅពីក្មេងសប្បាយហួស ។

ប៊ុនថន: ចឹងពូមានបានដើរលេងតែឯងទេ?

ហម: អត់ទេ ។

ប៊ុនថន: ចឹងបានតែទៅជាមួយចិនទេ?

ហម: បានតែជាមួយចិនដែរ ដើរតែឯងគេម៉េចឲ្យដើរ ។

ប៊ុនថន: ចឹងក្រុមពូអីមានបានចេញដើរដែរ?

ហម: បើដើរបានជិតៗទៅ គ្នាច្រើនបានដើរតែឯងមិនបានទេ ទៅយ៉ាងម៉េចកើតទាហានគេយាមជាប់ ។

ប៊ុនថន: ចឹងតាមផ្លូវមានទាហានរហូតឬយ៉ាងម៉េច?

ហម: មាន គេយាមកន្លែងទូតមានគេយាម ។

ប៊ុនថន: ចឹងខាងក្រៅដូចជានៅមុខវាំងអីមានទេ?

ហម: មុខវាំងខ្ញុំទៅកាលដែលខ្ញុំទៅពីសៀមរាបទេ កាលខ្ញុំទៅដល់ ដល់ខ្ញុំនៅកន្លែងទូតចិនហើយមិនដែលបានមកទេ ។

ប៊ុនថន: ចឹងកាលទៅយកដីរនៅកំពង់ផែនោះ?

ហម: យកនៅខាងមាត់ទន្លេឯនោះ ។

ប៊ុនថន: ចឹងតាមផ្លូវមានប៉ូលីសមានទាហានអីយាមទេ?

ហម: មានគេយាមតាមគោលដៅគេ ដូចថានៅក្បោងទ្វារស្ពានហ្នឹងគេយាមមួយកន្លែង អាស្ពានជ្រោយចង្វាហ្នឹង គេមានគេយាម ។

ប៊ុនថន: ចឹងឡានពូទៅ?

ហម: ឡានចិនទៅគេអត់មានកាក់ទេ គេអត់មានអើពើទេ ។

ប៊ុនថន: គេដឹងតែម្តង?

ហម: គេដឹង ។

ប៊ុនថន: គេឃើញចិននៅក្នុងហ្នឹង?

ហម: ឃើញចិននៅហ្នឹង មានពីណាហ៊ានធ្វើអី ។

ប៊ុនថន: មានដែលហៅឈប់អីទេ?

ហមៈ		អត់ទេ  អត់មានដែលកាត់ទេ ។

ប៊ុនថនៈ		ពូមានខស្សាហ៍ទៅផ្សារថ្មីច្រើនដងទេពូ?

ហមៈ		ទេ  រាប់មិនអស់ទេ  និយាយទៅតែគេត្រូវការគេទៅយកថ្នូ  ទៅយកស្អីណាហ្នឹងគេហៅទៅហើយ ។

ប៊ុនថនៈ		និយាយថាទៅផ្សារថ្មីទិញអីឥវ៉ាន់មានដែលទេ?

ហមៈ		អត់ទេ  ទៅទិញឥវ៉ាន់យើងមិនដែលទៅទេ ។

ប៊ុនថនៈ		ទៅជាមួយចិនណាស់?

ហមៈ		អត់ទេ  ចិនគេទៅទិញ  យើងទៅចេះទៅ  ចិនគេចុះទិញតិចតួចទៅណាស់  គេទិញអីស៊ីដឹង ។

ប៊ុនថនៈ		ភាគច្រើនគេទិញអីវិញ?

ហមៈ		គេទិញម្ហូបម្ហារអីទៅចិនហ្នឹង ។

ប៊ុនថនៈ		តែគេមានលុយទេ  ទិញហ្នឹង?

ហមៈ		មិនដឹងជាលុយស្អីគេ    បើយើងនៅតែលើឡាន    មិនដឹងជាគេចាយលុយមិនដឹងជាគេកក់យ៉ាងម៉េចមិនដឹង  ដូចជាមិនឃើញចាយឃើញអីទេ ។

ប៊ុនថនៈ		ទៅយកតែម្ហូប?

ហមៈ		ទៅយកតែម្ហូប«ក១៩»ហ្នឹងត្រីហ្នឹងគេទៅយកដែលដូចជាមិនឃើញឲ្យលុយទេ ។

ប៊ុនថនៈ		បាទ ។

ហមៈ		ចុះបើយើងវាមិនដឹងនោះ  ឃើញតែគេទៅយក  ទៅគេដូសឲ្យទៅមកបាត់មក ។

ប៊ុនថនៈ		បាទ ។

ហមៈ		តែគេនិយាយគ្នាយ៉ាងណាមិនដឹង    ហើយយើងគេយកអីទៅឲ្យស៊ីក៏មិនដែលឃើញឲ្យលុយគេ  អន្ទង់ត្រីអីគេដឹក  មិនដែលឃើញឲ្យលុយគេ ។

ប៊ុនថនៈ		តែមានសំបុត្រអីទេ?

ហមៈ		មិនបានដឹងផង  រឿងសំបុត្រមិនដឹងទេ  ដឹងគេនិយាយគ្នាយ៉ាងម៉េច  ខ្ញុំនៅកន្លែងទូតចិនហ្នឹងទៅភ្នំពេញទៅចូកខ្សាច់នៅកំពង់ត្រាំនោះមួយសារទៅ  តាមឡានណាស់ ។

ប៊ុនថនៈ		បាទ ។

ហមៈ		ទៅចូកខ្សាច់យកមកធ្វើកន្លែងទូតចិនហ្នឹង ។

ប៊ុនថនៈ		បាទ ។

ហមៈ		ទៅនោះក៏ច្រើនដែលយកខោអាវជជុះទៅជួយឲ្យប្រជាជនហ្នឹង  ជិតកំពង់ត្រាំ ។

ប៊ុនថនៈ		កំពង់ត្រាំនៅកន្លែងណាវិញ?

ហមៈ កន្លែងខ្សាច់ច្រើនហ្នឹងស្ទឹងហ្នឹង ។

ប៊ុនថនៈ ខាងកំពង់ស្ពឺ ខាងកំពង់សោមហ្នឹង?

ហមៈ ទេ ផ្លូវមកខាងពោធិចិនតុងហ្នឹងឯង ។

ប៊ុនថនៈ ហ្នឹងហើយផ្លូវបុកទៅកំពង់សោម?

ហមៈ ហ្នឹងហើយ គេហៅថាកំពង់ត្រាំៗ កន្លែងចូកខ្សាច់ណាស់ ។

ប៊ុនថនៈ បាទ ។

ហមៈ យកខោអាវចាស់ឲ្យប្រជាជនទៅស៊ើច... ។

ប៊ុនថនៈ អរចែក?

ហមៈ ហ្នឹងហើយស៊ើច...សប្បាយដែលតើ ។

ប៊ុនថនៈ ទៅមួយកងមានគ្នាប៉ុន្មាននាក់ពូ?

ហមៈ យី!ទៅចូកខ្សាច់ច្រើនណាស់ ឡានបួនដបឡាននោះ ប៉ែលម្នាក់មួយ ទៅចូក ទុយឡានមក ចូកដាក់ៗ ។

ប៊ុនថនៈ ខោអាវជជុះយកពីណាទៅវិញ?

ហមៈ យកពីកំពង់ត្រាំទៅដាក់កន្លែងទូតចិនយើង ។

ប៊ុនថនៈ អត់ទេ និយាយខោអាវជជុះពូយកពីណាទៅវិញ?

ហមៈ យកពីភ្នំពេញទៅ ដើរចែកចាស់ៗតាមផ្ទះ ។

ប៊ុនថនៈ ប្រមូលទៅ?

ហមៈ បាទ!យកទៅ ដល់លើកក្រោយគេដឹងគេមិនឲ្យយកទៅ ប្រជាជនបុកមកខ្ទាចឡានយើង បុក ។

ប៊ុនថនៈ ប្រជាជនដណើមគ្នា?

ហមៈ ហ្នឹងហើយ ។

ប៊ុនថនៈ យកទៅបស់តែម្តងឬមួយហុច?

ហមៈ ឲ្យហុចទៅដល់ចឹងវារញ៉េរញ៉ៃគេឈប់ឲ្យយកទៅ ។

ប៊ុនថនៈ និយាយថាសប្បាយ?

ហមៈ សប្បាយដែរ ។

ប៊ុនថនៈ ចឹងក្រៅពីយកខោអាវទៅឲ្យពូមានដែលយកម្ហូបទៅឲ្យទៅទេ?

ហមៈ មិនមានទេ យើងអាហ្នឹងរបស់គេ គេមិញឲ្យយើង បានខោអាវជជុះតាមផ្ទះហ្នឹងចេះតែ យកទៅ ។

ប៊ុនថន: នឹកឃើញយ៉ាងម៉េចបានយកខោអាវទៅឲ្យហ្នឹង?

ហម: ទេ មិនដឹងជានឹកឃើញយ៉ាងម៉េចចេះតែយកទៅឲ្យទៅ ឃើញប្រជាជននោះ ។

ប៊ុនថន: បាទ! ចឹងប្រជាជនទៅតាមផ្លូវឬមួយក៏?

ហម: នៅតាមផ្លូវ ។

ប៊ុនថន: នៅស្រែនៅអី?

ហម: តាមផ្លូវយើងទៅចូកខ្សាច់ហ្នឹង ។

ប៊ុនថន: ប្រជាជនច្រើនទេ?

ហម: ច្រើន ពពាក់ពពើង អាវអីក៏មិនសល់ដែរ ។

ប៊ុនថន: ចឹងក្រៅពីចូកខ្សាច់ពូមានបានទៅណាទៀតទេ?

ហម: អត់ទេ មានបានទៅណាទេ នៅកន្លែងទូតចិនហ្នឹងគេដកឲ្យទៅនោះវិញទៅធ្លាយមកធ្វើខ្មែរក្រហមទៀតដល់សព្វថ្ងៃនេះ និយាយទៅរឿងប្រវត្តខ្ញុំវាកម្មហួស ។

ប៊ុនថន: ចឹងពូបានដើរច្រើនកន្លែងនៅទូតចិនហ្នឹង?

ហម: បាទ!បានដើរកាលនៅជាមួយភ្ញៀវហ្នឹងហើយបានដើរ កម្មណាស់និយាយទៅប្រវត្តកម្មហួស មិនសមហ្នឹងរស់ផង ។

ប៊ុនថន: បាទ ។

ហម: មែនណាសម័យកសាងហ្នឹងយ៉ាប់ណាស់ខ្ញុំ ។

ប៊ុនថន: តែពូបាននៅភ្នំពេញបានដើរច្រើនកន្លែង?

ហម: បាទ!នៅជាមួយភ្ញៀវហ្នឹងឯង កក់ក្ដៅជាមួយភ្ញៀវហ្នឹង ។

ប៊ុនថន: ចឹងកាលនៅហ្នឹងអត់មានចេះភាសាចិនទេ?

ហម: អត់ទេ ចិនយើងស្ដាប់បានដូចខ្ញុំប្រាប់ចឹងណាស់ ។

ប៊ុនថន: បាទ ។

ហម: ប្រើយើងឲ្យយកប៉ែល ឲ្យយកដែកឈូសអីស្ដាប់បាន ។

ប៊ុនថន: ចឹងពូទៅជាមួយចិនហ្នឹង ពូនៅជាមួយគីលីកម្មករឬទៅជាមួយមេ?

ហម: ទេ កម្មករដូចគ្នា ។

ប៊ុនថន: តែចិនហ្នឹងមានមេគ្រប់គ្រងទេ?

ហម: មាន មេគេយូរៗគេមកម្ដង គេមកបញ្ជាំងកុនឲ្យយើងមើលទៅ ។

ប៊ុនថន: មេហ្នឹងមកមានអ្នកយាមអីទេ?

ហម: អូស!ទាហានយាម ។

ប៊ុនថន៖	ចឹងខាងខ្មែរយើងមានមេៗទៅដែលទេ?

ហម៖	ទេ ដូចជាមិនដែលឃើញមានពីណាទៅផង ឃើញតែ តា ម៉ុលនៅហ្នឹងឯង ។

ប៊ុនថន៖	ចឹងតា ប៉ង់អីមានដែលឃើញទៅទេ?

ហម៖	មិនដែលឃើញទៅផង តា ប៉ង់ តា ព្រំអីមានដែលឃើញទៅទេ តា ម៉ុលនៅ ឃើញចិន ម៉ាប់ទៅៗ ។

ប៊ុនថន៖	ចឹងពូមានអីបន្ថែមប្លែកពីហ្នឹងទេពូ ដូចថាពូចាំជាងគេ?

ហម៖	ទេ ដូចជាអត់មានទេ វាអស់ហើយ ខ្ញុំមានតែប្រវត្តតស៊ូចឹងឯងសើច...។

ប៊ុនថន៖	បាទ!ចឹងពូមានអីដែលពូធ្លាប់ឆ្លងកាត់ហើយពូចាំគិតថាពីបាកឬមួយស្រួលឬមួយយ៉ាងម៉េច ?

ហម៖	ទេ អារឿងពិបាកនោះមាន ។

ប៊ុនថន៖	បាទ ។

ហម៖	ចាំមើលខ្ញុំប្រាប់ឆ្នាំ២០០៣នេះ ។

ប៊ុនថន៖	បាទ ។

ហម៖	ឆ្នាំ២០០៣ថ្ងៃទី២៩ គេប្ញន់ខ្ញុំ ខ្ញុំដេកគ្រែនេះឯងកូនខ្ញុំដេកអានោះហ្នឹង ។

ប៊ុនថន៖	បាទ ។

ហម៖	វាចងខ្ញុំ ខ្ញុំមិនឲ្យចង វាសុំខ្ញុំចងខ្ញុំមិនឲ្យចងវាចូលបីនាក់អាមួយឈរ មួយនៅនោះវាភ្ជុងខ្ញុំ ត្រង់នេះ ។

ប៊ុនថន៖	បាទ ។

ហម៖	ឆ្នាំ២០០៣ ថ្ងៃទី២៩ ។

ប៊ុនថន៖	តែអត់អីទេ?

ហម៖	អត់អីទេ ខ្ញុំថាមិនបាច់បាញ់ទេ លុយកាក់ខ្ញុំឲ្យអស់៣០ជាង ។

ប៊ុនថន៖	៣០ម៉ឺនលុយបាត?

ហម៖	៣០ម៉ឺនលុយបាត ។

ប៊ុនថន៖	ច្រើនដែរ?

ហម៖	បាទ!ប្ញន់ ។

ប៊ុនថន៖	៣០បាតហ្នឹងប៉ុន្មានទៅពូ?

ហម៖	៣០ម៉ឺនបាតហ្នឹង ២ទៅ៣សែនបើគិតជាសែន ។

ប៊ុនថន៖	៣សែន បើគិតជាលុយខ្មែរវិញប៉ុន្មានលានទៅ?

ហមៈ អូ! ៣០ លានដាន ។

ប៊ុនថនៈ ៣០ លានដាន ។

ហមៈ ខ្ញុំនៅពីរនាក់កូនខ្ញុំអានេះឯង អាហ្នឹងការហើយ កូនខ្ញុំអាបងការហើយនៅមាត់អូរលែងតែលក់ដូងនៅត្រង់នោះ ប្រពន្ធខ្ញុំទៅស៊ីបន្លែមនៅត្រង់នោះ ។

ប៊ុនថនៈ ពេលយប់ពូ?

ហមៈ ពេលល្ងាចម៉ោង៧ហ្នឹង ។

ប៊ុនថនៈ ម៉ោង៧?

ហមៈ ហ្នឹងហើយគេប្ចូនចូលមក កាំភ្លើងពីរដើមពូថៅមួយដើម ។

ប៊ុនថនៈ ចឹងយកទៅអត់មានធ្វើបាបពូដែរ?

ហមៈ អត់ទេ គេសុំខ្ញុំចង ឡើងទៅលើខ្ញុំឲ្យគេធាក់ទូយកទៅ ទូបែកឡើងខ្ទិចខ្ទីរអស់ ខ្ញុំក្រោកទៅខ្ញុំឈរត្រង់នេះឯង ទល់មុខគ្នា ខ្ញុំមើលមុខគ្នាស្គាល់ ខ្ញុំថាមិនបាច់បាញ់ទេចាំខ្ញុំឲ្យ ។

ប៊ុនថនៈ ចឹងមានតែប៉ុណ្ណឹងទេពូ?

ហមៈ មានតែប៉ុណ្ណឹងឯង ដែលកម្មវេទនាអាហ្នឹងឯងខ្លាំង ។

ប៊ុនថនៈ ចឹងខ្ញុំអរគុណលោកពូច្រើនហើយ?

ហមៈ បាទ ។

**«ចប់»**